– Reçu le 10 – 3 – 52 –

INDOCHINE FRANÇAISE DÉPÔT LÉGAL

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

"Revue de l'Instituteur khmer"
– partie cambodgienne –

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៣ លេខ ៧

ខែមិនា ព.ស. ២៤៩៥
Mars

ឆ្នាំសិក្សា ១៩៥១-១៩៥២.

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K-2
1951-1952
(7)

# ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្តីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្តី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ

ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា ........................ ៣

មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា ........................ ១១

កុមារដ្ឋាន - បរិវច្ឆណដ្ឋាន ភាសា ........................ ២៧

អាទិកដ្ឋាន — មជ្ឈិមដ្ឋានទី ១ — នព្វន្ត — វង្វាស់វង្វាល់

រណីមាណសាស្ត្រ ........................ ៣៥

កុមារដ្ឋាន បរិវច្ឆណដ្ឋា - នព្វន្ត - វង្វាស់វង្វាល់ ........................ ៥៤

អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ...... ៦៤

បរិវច្ឆណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ ........ ៧៦

លោកនីតិ សំរាប់គ្រប់ថ្នាក់ ........................ ៨១

មេសូត្រតែមាត់ ........................ ៨៤

# ឧត្តមដ្ឋាន

## ឧស្សាហកម្ម

ក្នុងសម័យបុរាណ មុនកំណើតកសិកម្ម មនុស្សទាំងឡាយតែងតែរកចិញ្ចឹមជីវិតដោយការផ្សេងៗ ដូចជាជីកដំឡូងមើមឈើ បុសឈើទីងទាប់សត្វស៊ីជាអាហារ ជីករូងបូចូលជ្រកតាមរអាងរហែងថ្ម យកស្បែកសត្វ ទីងស្លឹកឈើធ្វើជាគ្រឿងស្លៀកពាក់ នេះល្មមឃើញច្បាស់ថា ឧស្សាហកម្មមានមកហើយតាំងអំពីកាលដំបូងជាអង្វែងណាស់ ។

កាលបើឧស្សាហកម្មជាគោលធំក្នុងការចិញ្ចឹមជីវិតរបស់មនុស្សដូច្នោះ ក្នុងកាលតមកប្រទេសផ្សេងៗ ដែលចាត់ចែងគ្រោងការសេដ្ឋកិច្ចក៏សម្រេចព្រមទទួលយកឧស្សាហកម្ម ទុកជាគ្រឹះដូងរបស់សេដ្ឋកិច្ចទៅ ព្រោះមនុស្សទាំងឡាយដែលមានជីវិតរស់នៅក្នុងលោក សុទ្ធតែមានសេចក្តីត្រូវការដូចគ្នាទាំងអស់ ។

កាលបើគ្រប់ប្រុកគ្រប់អន្លើសឹងមានសេចក្តីត្រូវការកាន់តែច្រើនហើយថែមឡើងយ៉ាងនេះជាហេតុឲ្យមានអ្នកគិតប្រឌិតវត្ថុផ្សេងៗឲ្យមានលក្ខណៈវិសេសឡើង ដើម្បីឲ្យសមតាមបំណងរបស់អ្នកត្រូវការ ហេតុនេះឯងបាន

ជាធម្មជាតិផ្សេងៗត្រូវបានគាត់តែងដោយកម្លាំងសតិបញ្ញារបស់មនុស្សៗ ហេតុនេះបានជាមានអ្នកគិតបង្កើតគ្រឿងម៉ាស៊ីនឧស្សាហកម្មឡើង ។

កាលបើមនុស្សយើងត្រូវនាំយកធម្មជាតិនិងវត្ថុផ្សេងៗមកប្រឌិតធ្វើឡើង ហើយផ្សាយដល់មនុស្សលោកដែលមានសេចក្ដីត្រូវការ រកទីបំផុតគ្មាន ដូច្នេះហើយឧស្សាហកម្មក៏កាន់តែបណ្ដុះបណ្ដាលបង្កើតរបស់ចំឡែកៗ ឲ្យមានច្រើនឡើងជាអនេកប្រការ, ដូចអគ្គិសនី, ទឹកកក, ម៉ាស៊ីនច្រៀង, វិទ្យុ, រថយន្ត, រថបម្បាំង, រថភ្លើង, កប៉ាល់ យន្តហោះនិងបណ្ដានានាវត្ថុជាអនេកប្រការដទៃទៀត ហើយឧស្សាហកម្មនៅបង្កើតផលានុផលឲ្យដល់ប្រទេសផ្សេងៗជាច្រើនប្រការដោយឡែកទៀត ។ ហេតុនេះហើយ ឧស្សាហកម្មផ្សាយចេញទៅគ្រប់ៗប្រទេសក្នុងលោក ។ (សេចក្ដីសំរាំង - ប.ឈុំ)

## ពន្យល់ពាក្យ

ឧស្សាហកម្ម = (ម-ថ-ស៊ុស-សា ហៈ ក័ម) = ការធ្វើរបរអ្វីឲ្យកើតបាន ជាដំនួញទូទៅ ។

កសិកម្ម = ការធ្វើស្រែចម្ការ (ភ្ជួររាស់)

គ្រោងការ = សណ្ឋានការ

សេដ្ឋកិច្ច ឬ សេដ្ឋកម្ម=(ម-ថ-សេត-ថ...)=ការឬកិច្ចការប្រសើរផុត

(មុខរបរដ៏ឧត្តម)

ប្រឌិត = ផ្ដើមឡើង

## ការហត្ថកម្ម

ការហត្ថកម្មមានច្រើនប្រភេទ ដូចជាធ្វើជាងឈើ ជាងគំនូរជាងស្មិត ជាងក្បាច់ ជាងក្រឡឹង ជាងប្រាក់ ជាងមាស និងការត្បាញ ការដេរ ប៉ាក់និងការច្ងៃឯទៀតរហូតដល់ការកសាង ។ ការតាំងពេងភារឈើ ម៉ាស៊ីនកិនស្រូវ គ្រឿងដំបាញនិងគ្រឿងប្រើប្រាស់ជាដើម ។ ក្រៅពីនេះនៅមានរបរចិញ្ចឹមជីវិតដទៃទៀតជាច្រើនយ៉ាង ដូចជាពេទ្យស្មាក្ដី ឈ្មោន និងការស៊ីឈ្នួលជាដើម ក៏ហៅថា របរចិញ្ចឹមជីវិតទាំងអស់ ។

របរចិញ្ចឹមជីវិតទាំងនេះ ជារបរដែលត្រូវធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនក៏មាន សម្រេចចិត្តរួមគំនិតគ្នាធ្វើក៏មាន រួមហៅថាករណីយកិច្ច ព្រោះជាកិច្ចដែលយើងត្រូវធ្វើខានពុំបាន ។ នៅមានការងារម្យ៉ាងទៀត ដែលជាការងារនៅក្នុងក្រសួងរាជការ ឬរដ្ឋបាល ដែលយើងត្រូវធ្វើការនៅក្រោមបង្គាប់ជាជាន់ៗថ្នាក់ៗ តាំងពីដេបតីថ្នាក់ខ្ពស់បំផុតរហូតមកដល់ស្មៀនស្នូរ ភ្នាក់ងារថ្នាក់ទាប ការធ្វើរាជការនេះជារបរចិញ្ចឹមជីវិតមួយដែរ ព្រោះអ្នក

រាជការរមែងបានប្រាក់ខែជាគ្រឿងចិញ្ចឹមជីវិតរាល់ខែ ប៉ុន្តែអ្នកធ្វើរាជការគោងតែមានចំណេះវិជ្ជាខ្ពង់ខ្ពស់ប្រព្រឹត្តសុចរិតក្នុងនាទីមុខក្រសួងនោះៗ - តាមព្រះរាជបញ្ញត្តិ ។ របរចិញ្ចឹមជីវិតយ៉ាងនេះ រាប់ថាជាកិច្ចការចិញ្ចឹមជីវិតដ៏ត្រឹមត្រូវ តាមសេចក្តីនិយមក្នុងលោក មិនខុសនឹងច្បាប់សម្រាប់ស្រុក គួរតែយើងរើសរកធ្វើតាមចំណេះវិជ្ជារៀងខ្លួន ៗ មានការចិញ្ចឹមជីវិតម្យ៉ាងទៀតខុសនឹងច្បាប់សម្រាប់ផែនដី ដូចជាការឆបោក កុហក បញ្ឆោត លួចប្លន់ជាដើម របរចិញ្ចឹមជីវិតបែបនេះ យើងមិនត្រូវប្រព្រឹត្ត ព្រោះនាំឲ្យខូចប្រយោជន៍អ្នកដទៃ តាំងកើតទុក្ខទោសដល់ខ្លួនផង ។

(សេចក្តីសំពង- ប-ឈុំ)

## ពន្យល់ពាក្យ

ប្រភេទ= បែប យ៉ាង ...

ហត្ថកម្ម= (ម ថ. ហ័តថៈក័ម) ការដែលត្រូវធ្វើដោយដៃ ...

ស្ម័គ្រ= ព្រមព្រៀង

អធិបតី= (ម ថ អៈធិប៉ៈដី) ន. អ្នកដែលជាធំ ...

ស្មេរ= ន. អ្នកសរសេរ (ស្មៀន) ។

វេវចនៈ: ស្មគ្រ=ព្រមព្រៀង=ស្រុះចិត្ត–ពេញលេញ–ពេញចិត្ត ...

សទិសសព្ទ: រៀង–កិ. រៀងលេខ ។ កិ. វិ. ឈររៀងគ្នា ។ គុ. លេខរៀង ។ រាង–កិ· ប្តុ. ចំរាងហើយ–រាងចាល–រាងមិនឈ្នះ រាគ ។ រាង·ន.ដេញ·រាង ។

អក្ខរាវិរុទ្ធ: គំនូរ(រ)–ដេរ(រ)–អារ(រ)–ដំបាញ ប្តដម្បាញ ប្តតំបាញ ។ ស្មគ្រ(គ្រ)·ទុក្ខ(ក្ខ) ។

សួរចោទ.– យ៉ាងដូចម្តេចដែលហៅថាការហត្ថកម្ម? ចូររៀបរាប់ការហត្ថកម្មដែលអ្នកស្គាល់ ។ អ្នកចូលចិត្តរបរណា? ពីព្រោះអ្វី ។ល។

---

### មេរៀនទី ២

## ការចិញ្ចឹមជីវិត

ការចិញ្ចឹមជីវិត របស់មនុស្សយើង មានច្រើនយ៉ាងច្រើនប្រការ ផ្សេងៗគ្នាស្រេចតែអ្នកឯណាមានចំណេះចេះស្ទាត់ខាងផ្លូវណា ក៏ធ្វើការខាងផ្លូវនោះដើម្បីឲ្យបានទ្រព្យមកចិញ្ចឹមជីវិត ចាយវាយទុកដាក់ស្រេច ។ កាលបើគេទ្រព្យបានមកល្មមស៊ីចាយហើយ ដែលសេសសល់ពាំងប៉ុន្មាន ក៏បែកចាយចំណាយផ្លាស់ប្តូរគ្នា ។ ប្រភេទនៃការចិញ្ចឹមជីវិតរបស់មនុស្ស

យើងនេះស្រេចតែភូមិប្រទេសឬទីដំបន់ដែលខ្លួននៅ គឺបើថានៅជិតសមុទ្រ, ទន្លេ, ស្ទឹង, បឹងបួ គេតែងរកបរនេសាទត្រី ។ អ្នកដែលនៅកន្លែងមានរ៉ែផ្សេងៗក្នុងដីក៏ធ្វើការជីកយករ៉ែដែលហៅថាលោហកិច្ច ។ អ្នកដែលនៅជិតព្រៃ ក៏ធ្វើការកាប់ឈើក្នុងព្រៃយកឈើមកលក់ ។ អ្នកដែលនៅលើដីរាបមានទឹកលិចមានដីជីជាតិ ក៏ធ្វើកសិកម្មដូចធ្វើស្រែចំការច្បារដំណាំនិងចិញ្ចឹមសត្វ ។ ឯអ្នកដែលនៅក្នុងទីប្រជុំជនដូចទីផ្សារ ក៏ធ្វើការលក់ដូរ ដែលហៅថាពាណិជ្ជកម្ម និងចាត់ចែងធ្វើគ្រឿងឧបភោគបរិភោគតាមសេចក្តីត្រូវការរបស់មនុស្សខ្លួនទៅ ហើយចេញជាជំនួញដែលហៅថារបរហត្ថកម្មនិងសិល្បកម្ម ។ (សេចក្តីសំរាំង ច-ឈុំ)

## ពន្យល់ពាក្យ

រ៉ែ= លោហធាតុផ្សេងៗកើតនៅក្នុងដី (រ៉ែដែក, ស្ពាន់សំណ) ពាក្យបារាំង មីន mine ។

លោហកិច្ចឬលោហកម្ម= ការធ្វើលោហៈ (ដែក-ស្ពាន់)

ពាណិជ្ជកម្ម= (ម.ថ. ពានិច-ជៈក័ម) ន. របរលក់ដូរ ។ ពានិជ្ជ ឬពាណិជ្យ= ជំនួញ ។ ពាណិជ= អ្នកជំនួញ ។

ឧបភោគ= (ម.ថ.អ៊ុប៉ៈភោគ) គ្រឿងសម្រាប់ប្រើប្រាស់ជិតខ្លួនៗ

សិល្បកម្មឬសិប្បកម្ម (ម.ថ. សិលប៉ៈកម័ ឬសិប៉ៈកម័) ការងារផ្សេងៗ ។

ទួទៅឬទូទៅ= គិ. ប្រព្រឹត្តទៅបានសព្វ-ផ្សាយសព្វទៅ ។

សន្ធានពាក្យ= ប្ដូរ: ដូរ-ថ្ងូរ

វេវចនៈ: ប្រភេទ: បែប-យ៉ាង-ចំណែក-បែបបទ

អក្ខរាវិរុទ្ធ: ប្ដូរ ឬផ្ដូរ (រ) ប្រភេទ (ទ) សមុទ្រ (ទ្រ) កិច្ច (ច្ច)

សួរបោទ.– មនុស្សយើងមានការចិញ្ចឹមជីវិតដូចគ្នាឬទេ ។ ពីព្រោះអ្វី ។ ហេតុអ្វីបានជាប្រភេទ នៃការចិញ្ចឹមជីវិតរបស់មនុស្សខុសពីគ្នា ។ ល ។

## របរចិញ្ចឹមជីវិតក្នុងស្រុក

ហេតុដែលមនុស្សយើងមានរបរចិញ្ចឹមជីវិតផ្សេងៗគ្នានោះ តាមធម្មតាច្រើនតែទាក់ទងនឹងភូមិប្រទេស - ទីដំបន់ដែលខ្លួនអាស្រ័យនៅ ប្រទេសយើងជាប្រទេសមួយដែលមានអាកាសក្ដៅនៅក្នុងឥណ្ឌូចិន រមែងមានភ្លៀងធ្លាក់ចុះតាមរដូវតែរៀងរាល់ឆ្នាំ អាណាខេត្តជាងមួយសែនគីឡូម៉ែត្រក្រឡា មានដីរាបមានទីទំនាបមានព្រែក មានភ្នំ ទន្លេ ស្ទឹង អូរ

បឹងតូចធំជាច្រើន ៗ ឯផ្លូវគមនាគមន៍ទាំងខាងក្នុងស្រុកនិងក្រៅស្រុកក៏ស្រួលឡើងចំរើនតាមសម័យ ដូចជារថភ្លើង រថយន្ត កប៉ាល់ជាដើម ៗ អាជីវកម្មរបស់ប្រជាជនជាតិខ្មែរ ដោយច្រើននិយមធ្វើរបរក្សេត្រកម្មដែលជាអាជីវកម្មធំបំផុតក្នុងប្រទេសយើង តែរបរក្សេត្រកម្មរបស់ជនជាតិយើងច្រើនតែធ្វើគ្រាន់តែល្មមស៊ីចាយ មិនធ្វើជារបរធំដុំដូចជាតិដទៃទេ ទុកជាមានខ្លះក៏មានចំនួនមិនច្រើនប៉ុន្មានដែរ តែទុកជាធ្វើតិចច្រើនយ៉ាងណាក៏ដោយ ក៏នៅមានចំនួនស្រូវមានចំណាយចេញទៅប្រទេសក្រៅជាចំនួនច្រើនតែរៀងរាល់ឆ្នាំ ៗ របរក្សេត្រកម្ម ដែលធ្វើនៅស្រុកយើងវេលានេះ មានការធ្វើស្រែចម្ការកប្បាស ថ្នាំជក់ អំពៅ ពោត ម្រេចដូង ម្ស្វាទឹង បន្លែឈើផ្លែជាដើមក្រៅពីរបរក្សេត្រកម្មមានរបរនេសាទត្រី និងឈើព្រៃទៀតផង ៗ (សេចក្ដីសំរាំង- ប. ឈុំ)

## ពន្យល់ពាក្យ

គមនាគមន៍= ផ្លូវកាន់គ្នាទៅវិញទៅមក ៗ

អាជីវកម្ម= ការចិញ្ចឹមជីវិត

ក្សេត្រកម្ម= របរស្រែចម្ការច្បារដំណាំ

សទិសសព្ទៈ ថេ ធេះថេ ៗ តេ់–កិ.តេ់លឿន ៗ តុ-កិ. តុគ្រើ ៗ

អក្ខរាវិរុទ្ធ= បេះ (រ)– ភ្លៀង ឬ ផ្លៀង – ក្បេគ្រ (ក្ប)

សួរបោទ– ប្រទេសយើងមានធាតុអាកាសយ៉ាងដូចម្ដេច ? ៗ មានប៉ុន្មានរដូវ ? ៗ របរអ្វីដែលធំបំផុតរបស់ជនជាតិខ្មែរ ៗ គេធ្វើរបរស្រូវនៅរដូវណា ? ៗ ល ៗ

---

# មជ្ឈិមដ្ឋានទី១

## រៀនមើល – ហាត់ភាសា

### អាទិត្យទី ១.- បុត្រធីតានិងមាតាបិតា

បែបបទដែលបុត្រធីតាត្រូវគោរព ត្រូវទំនុកបំរុងមាតាបិតាវិញមានប្រាំយ៉ាង :

១.– ចិញ្ចឹមរក្សាមាតាបិតាដោយពេញលេញ ឲ្យដូចកាលមាតាបិតាចិញ្ចឹមរក្សាខ្លួន ឬបើមានលើសជាងនោះទៅទៀត ក៏រឹងរឹតតែប្រសើរណាស់ ៗ

២.– ធ្វើកិច្ចការជំនួសមាតាបិតា មិនគោះគើយ សោះអង្គើយ បណ្ដែតបណ្ដោយឲ្យមាតាបិតានឿយហត់ទាល់ចាស់ ទោះបីខ្លួនមានស្វាមីភរិយាបែកមុខការរបរចេញឃ្លាតពីមាតាបិតាហើយ ក៏ត្រូវតែជួយធ្វើកិច្ចការរបស់មាតាបិតាតាមកាលវេលាម្ដងៗ ដែលគួរនឹងខានពុំបាន ។

៣.– តាំងវង្សត្រកូលល្អរបស់មាតាបិតាឲ្យគង់នៅ គឺមិនបំបាត់សណ្ដាប់ធ្នាប់ល្អរបស់មាតាបិតាឲ្យវិនាស មិនប្រព្រឹត្តល្មើសរំលងនូវល្អរបស់មាតាបិតា មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤.– គោរពប្រតិបត្តិឲ្យល្មមមាតាបិតាពេញចិត្តឲ្យទ្រព្យសម្បត្តិកើតសម្បាប់ ប្រយ័ត្នរក្សាទ្រព្យសម្បត្តិកេរ្តិ៍អាករ ដែលមាតាបិតាចែកឲ្យ មិនបំផ្លាញឲ្យវិនាសអសារឥតការ ។

៥.– លុះឥតអំពីមាតាបិតាទៅ បានលើកសពសំស្ការដោយគោរព បានធ្វើទក្ខិណានុប្បទាន ឧទ្ទិសផលបុណ្យជូនរឿយៗ ។

មាតាបិតានឹងបុត្រធីតា ដែលបានបំពេញកិច្ចរបស់ខ្លួន តាមបែបបទដូចមាននិទានមកនេះ ទើបពេញជាបុត្តការីកតញ្ញូកតវេទីត្រឹមត្រូវ ។

(មើលមេរៀនទី ៦ អំពី "មាតាបិតានឹងបុត្រធីតា" ផង) ។

ព្រះពុទ្ធឃោសាចារ្យ ជ.ណាត

(សេចក្ដីសំពង់លោកអ៊ុំ-ឈុំ) ។

## អាននិងពន្យល់ពាក្យ

គោរព– ន. ប្ក. កិ. = សេចក្តីលំអុត–ឱនលំទោន កោតក្រែង ។

ឱវាទ– ដំបូន្មាន ។ ស្តាប់ឱវាទ ។

អាករ– កំណាប់ទ្រព្យ ។

អសារ – (ម.ថ.អ:សា) = ដែលឥតខ្លឹមឥតប្រយោជន៍ ។

សំស្ការ – (ម.ថ.ស័ង៍ស្កា)= សំរាម (លើកសពសំស្ការ គឺលើកខ្មោចរើសប្រមូលឆ្អឹងយកមកធ្វើបុណ្យ) ។

ទក្ខិណានុប្បទាន– (ម.ថ. ទក្ខិណានុបប:ទាន) ន. អំណោយដែលគេឧទ្ទិសផលនៃទក្ខិណាទាន ទៅបុគ្គលដែលចាកឋានទៅកាន់បរលោកហើយ ។

បុព្វការី– (ម.ថ. បុប ព:ការី) ន.= អ្នកដែលធ្វើឧបការៈមុន ។ មាតាបិតាជាបុព្វការីរបស់កូន ។ គ្រូជាបុព្វការីរបស់សិស្ស ។

កតវេទី– ន.ប្ក. = អ្នកដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមានគុណ ។

ស្សរបោទ– បែបបទដែលបុត្រធីតាត្រូវទំនុកបំរុងមាតាបិតាមាន

ប៉ុន្មានយ៉ាង ? បទទី ១ ត្រូវធ្វើដូចម្ដេចខ្លះ ? មនុស្សក្នុងលោកដែលប្រព្រឹត្តតាមបទទី ១ មានចំនួនច្រើនឬតិច ។ល។

## តែងសេចក្ដី

ចូរអធិប្បាយអំពីកិច្ចដែលអ្នកត្រូវបំពេញដល់មាតាបិតា អ្នកនឹងបានពេញជាបុត្តការី កតញ្ញូ កតវេទីត្រឹមត្រូវ ។

---

## សេចក្ដីសប្បុរស

ខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា តែងប្រដៅកូនចៅឲ្យកាន់ចិត្តសប្បុរសនឹងលោកសង្ឃ - នឹងសមណព្រាហ្មណ៍ យាចក ហើយឲ្យអាណិតមេត្តាដល់អ្នកកំសត់ទុគ៌តតោកយ៉ាកលំបាកផង ។ ហេតុដូច្នេះបានជាគេឃើញខ្មែរធ្វើបុណ្យឲ្យទានជារឿយ ៗ នៅក្នុងវត្តអារាម ហើយគេជួយមនុស្សក្រីក្រតោកយ៉ាកលំបាកឲ្យមានអាហារចិញ្ចឹមជីវិត ហើយនឹងសម្លៀកបំពាក់ល្មមសមគួរផង ។

ខ្មែរតះតិះដៀលមនុស្សណាដែលមានចិត្តជាអសប្បុរស - អកតញ្ញូនឹងអ្នកដ៏មានគុណមានមាតាបិតា - គ្រូអាចារ្យ ហើយនឹងអ្នកដែលជួយទំនុកបំរុងផ្គងផ្ដើមឲ្យបានប្រយោជន៍ផ្សេងៗជាដើម ។ គេមិនរាប់អាន

មនុស្សដូច្នេះសោះឡើយ គេស្អប់ហើយគេមិនយកជាមិត្តសំឡាញ់ទេ ។

ពោះជាមានសេចក្ដីទូន្មានល្អប្រកបដោយធម៌ដូច្នេះ ក៏គង់នៅមានមនុស្សខ្លះមានចិត្តកំណាញ់ណាស់ ។

មនុស្សខ្លះមិនដែលធ្វើបុណ្យឲ្យទានសោះ ហើយកំណាញ់ទឹងខ្លួនឯងផង ។

ហាត់ភាសា— ខ្មែរជាអ្នកកាន់សាសនាអ្វី ? ខ្មែរតែងប្រដៅកូនចៅឲ្យប្រព្រឹត្តដូចម្ដេច ? ខ្មែរត្មះតិះដៀលមនុស្សបែបណា ? គេស្រឡាញ់រាប់អានមនុស្សបែបនោះឬទេ ? ។

---

## អាជិកជ្ជន

### បង្រៀនពាក្យនិងភាសា

អាទិត្យទី ១.— អំពីគ្រឿងជាតិដែលមានសរសៃត្បាញបាន

នាម.— កប្បាស, គរ, ធ្មៃ, ម្ចាស់, បេក, ត្រគៀតបោ៉ង កៅស៊ូ, ឫស្សី, សំឡី, ជ័រ, សរសៃអន្ទង់, សរសៃចាក់, គី, ផ្កាះបោះកប្បាស សម្លៀកបំពាក់, សំពត់អម្បោះ ។

គុណនាម – ទន់, រឹង, ស្វិត, យឺត, ផាប់, ផុយ, តាំ, ធ្ងារ, ថោស, រលីង, រលើប, គគ្រាត ។

កិរិយាសព្ទ. – គាត់ខោ-អាវ, ដេរសំលៀកបំពាក់, បោះកប្បាស, គ្រាំគ្រះពោរ-ផ្ទៃ, រវៃអំបោះ, ថ្វេចសំឡី, ខារអំបោះ, អន្ទង, ត្បាញ, សក-សំបក ។

**ហាត់ភាសា.–** សំលៀកបំពាក់ដែលយើងស្លៀកពាក់សព្វថ្ងៃ បានមកពីអ្វីខ្លះ? (បានមកពីរុក្ខជាតិនិងសត្វ) ។ អ្នកស្គាល់រុក្ខជាតិអ្វីខ្លះដែលមានសរសៃត្បាញបាន ?- នៅភូមិអ្នកមានគេដាំកប្បាសឬទេ ? កប្បាសគេដាំច្រើននៅទីណា ? កាលណាផ្លែកប្បាសបែករីក គេធ្វើដូចម្ដេច?- គេយកកប្បាសទៅធ្វើដូចម្ដេចទើបបានជាសំឡី ?- ខ្មែរយើងយកសំឡីកកប្បាសទៅធ្វើអ្វី ?- (យកទៅធ្វើអម្បោះ ក្លួយ-ត្បាញសំពត់សំពប់គាត់ខោអាវ ធ្វើជាក្រមាជ្ជូតទឹក ធ្វើស្បៃមុង ។ ល ។

**ការហាត់សរសេរ.–** ១ ចូរឆ្លើយឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ៖

សម្លៀកបំពាក់ដែលយើងប្រើប្រាស់សព្វថ្ងៃបានមកពីអ្វីខ្លះ? រុក្ខជាតិណាខ្លះដែលមានសរសៃត្បាញបាន? ។ ២ សុំឲ្យរើសយកពាក្យនាម-គុណនាម-កិរិយាសព្ទ ខ្លះមកដាក់ឲ្យសិស្សតែងធ្វើជាឃ្លាផង ។

## បង្រៀនមើល

## សិប្បិយការកើតពីសត្វ

(សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១៥០)

ហាត់ការសា : សំពត់សូត្រយ៉ាងល្អគេធ្វើនឹងអ្វី?- ដើម្បីនឹងស្រាវយកសរសៃសូត្រអ្នកស្រុកអាយធ្វើដូចម្តេចខ្លះ?- ព្រោះអ្វីបានជាគេយកសំបុកសូត្រទៅស្រុសក្នុងទឹកពុះហើយក្រូវនឹងបង្កើះ គេស្រាវសូត្រនឹងអ្វី? ស្រាវរួចហើយគេធ្វើម្តេចទៀត? ។ល។

## សរសេរតាមសូត្រ

## អំពីដើមកប្បាស

ដើមកប្បាសជារុក្ខជាតិតូច កំពស់មួយម៉ែត្របុមួយម៉ែត្រកន្លះ គ្រាប់វាសម្បុរសឬលៀងមានសំឡីរុំព័ទ្ធជុំវិញ ផ្លែបែបជាឡូតមានគ្រាប់នឹងរោមទន់ល្មើយនៅក្នុង គឺរោមនោះហើយដែលហៅថាសំឡី ។ កប្បាសដុះលើដីល្អហើយមានជីជាតិច្រើនផង ។

គេដាំកប្បាសនៅខែបុស្ស-មាឃ ហើយគេបេះយកផ្លែវានៅខែជេស្ឋ ឬ អាសាឍ ។ នៅស្រុកខ្មែរ, គេដាំកប្បាសនៅមាត់ទន្លេមេគង្គ ក្នុងខេត្តកំពង់ចាមនិងខេត្តកណ្ដាល ។

កប្បាសសម្រាប់ត្បាញធ្វើជាសំពត់ ហៅថាសំពត់អម្បោះ គេយកគ្រាប់វាទៅស្លប្រេងសម្រាប់អុជ-លាងម៉ាស៊ីន ហើយនឹងធ្វើសាប៊ូកាកសម្រាប់ធ្វើដី ។

សរសេរពាក្យពិបាក.— កប្បាស-រុក្ខជាតិ-សម្បុរស-រុំ-ព័ន្ធ-ដុះ-បុស្ស-មាឃ-ជេស្ឋ-អាសាឍ-កំពង់-កណ្ដាល-ទន្លេ-ប្រេង-អុជ-លាង ។

## តែងសេចក្ដី ១

ចូរឆ្លើយតាមពាក្យចោទសួរខាងក្រោមនេះ៖

ពោតជាដំណាំគេដាំយកអ្វី? ដើមវាមានកំពស់ប៉ុន្មានម៉ែត្រ? ស្លឹកវាយ៉ាងដូចម្ដេច? ផ្កាវាមានប៉ុន្មានយ៉ាង? នៅដើមនិមួយៗមានផ្កាប៉ុន្មាន? គ្រាប់ពោតមូលមានពណ៌ដូចម្ដេច? ពោតមានប្រយោជន៍ដូចម្ដេចខ្លះ? ។

## អក្សរផ្ចង់

ព ឮ ឭ ឰ ញ ឱ

ពពែញី ស្រុកពញាឮ ឮគេហៅ ឭឯកាលណោះ ពៅ ពញារក្សាភិបាល ។

## បង្រៀនពាក្យ-ហាត់ភាសា

### អាទិត្យទី ២.– អំពីរោងកិនស្រូវ

*នាម.– ស្រូវ, ស្រូវខ្សាយ, ស្រូវដំណើប, អង្ករ, អង្កាម, ម្សៅ-កន្ទក់, ត្បាល់ជាន់ (ត្បាល់ក្ដឿង), ត្បាល់កិន, ត្បាល់បុក, អង្រែ, កញ្ច្រែង, កញ្ជើ, ល្អី, បាវ, រោងម៉ាស៊ីន (រោងចក្រ) ។*

*គុណនាម.– ធ្ងន់, ស្រាល, រហ័ស, យឺត, ខ្ចប, ល្អិត, ម៉ដ្ឋ, ជ្រាយ, ខ្មៅ, ស ។*

*កិរិយាសព្ទ.– កិន, ជាន់, បុក, បក់ឬអុំអង្កាម, រែងកន្ទក់, ហាលស្រូវ, រោយស្រូវ, ។*

ហាត់ភាសា.– គេធ្វើដូចម្ដេចដើម្បីនឹងយកអង្កាមចេញ? ត្បូរត្បាល់កិនខាងលើ - ខាងក្រោមយ៉ាងដូចម្ដេច? គេធ្វើនឹងអ្វី? ដើម្បីនឹងកិនស្រូវគេដាក់ដៃត្បាល់ទៅឯណា? គេច្រកស្រូវទៅឯណា? ត្បូរត្បាល់ខាងក្រោមភ្ជាប់ទៅនឹងអ្វី? លុះកិនស្រូវរួចហើយគេធ្វើដូចម្ដេចទៀត? ត្បាល់ជាន់បែបយ៉ាងដូចម្ដេច? អ្នកដែលជាន់អង្ករដែរឬទេ? គេជាន់ប៉ុន្មានសារទើបអង្ករស? ។ល។

ការហាត់សរសេរ.– ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ៖

ស្រូវ - អង្ករ - អង្កាម - កន្ទក់ - ម្សៅ ។

ឧទាហរណ៍.– ពីម្សិលមិញខ្ញុំជួយកិនស្រូវបងប្រុសខ្ញុំអស់ចំនួនប្រាំថាំង ។ គេយកអង្ករសំរូបទៅជាន់ឬបុកឲ្យសធ្វើជាអង្ករសំរិត ។

**បង្រៀនមើល**

## រោងកិនស្រូវ

(សៀវភៅវិត្តស្វាធ្យាយន៍ អាទិកដ្ឋានទំព័រ ៣២ តាំងពីមុននឹងយកស្រូវមកប្រើការ ... រហូតដល់ .... ឯនៅស្រុកហាណូយនឹងហៃហ្វុងហើយនឹងភ្នំពេញគេឃើញមានរោងកិនស្រូវដែរ ។

ពន្យល់ពាក្យ.— កិន = កិ. សង្កត់ឲ្យបែកៈ កិនស្រូវ, កិនគ្រួសៗ ជាន់ = កិ. ដាក់ជើងសង្កត់ស៊ិបពីលើ ៗ ជាន់អង្ករឬបុកអង្ករនឹងត្បាល់ ជាន់ឬនឹងត្បាល់បុក ៗ កញ្ច្រែង = ន. ប្រដាប់ប្រើត្បាញនឹងបន្ទោះដូចល្អី, កញ្ជើ តែត្បាញរង្វើលៗ កញ្ច្រែងរាងជ្រៅប្រហោងធំសម្រាប់ដាក់-ត្រី, កញ្ច្រែងរាងរាក់ប្រហោងតូចៗ សម្រាប់រែងអង្ករ ៗ ត្បាល់ = ន. ប្រដាប់សម្រាប់ប្រើខាងបុក, កិន, ជាន់, បក់ស្រូវជាដើម ៗលៗ ត្បាល់មានច្រើនយ៉ាងៈ ត្បាល់កិនមានមេគ្រប, គៅ, ធ្មេញ, ដៃសម្រាប់កិន-ស្រូវជាដើម ៗលៗ ត្បាល់ជាន់ឬត្បាល់ក្លៀង ត្បាល់ដែលមានអង្រែជាប់នឹងដងសម្រាប់ជាន់បុកស្រូវជាដើម ៗ

ហាត់ភាសានឹងហាត់សរសេរ.— (សូមធ្វើដូចមុន)

## សរសេរតាមសូត្រ

### អំពីហាលស្រូវ

កាលពីថ្ងៃអាទិត្យមុន មេឃស្រឡះ ព្រះអាទិត្យបញ្ចេញចំហាយខ្លាំងណាស់ ម្ដាយខ្ញុំបាទប្រើបងខ្ញុំនឹងខ្ញុំឲ្យហាលស្រូវព្រោះជិតអស់អង្ករបរិភោគហើយ នោះបងខ្ញុំហើយនឹងខ្ញុំបាទក៏យកកន្ទេលស្លឹកត្នោតមួយធំទៅក្រាលលើដីមួយកន្លែងរាបស្មើក្នុងទីធ្លា រួចយកកញ្ជើមួយកើបស្រូវពី

ជល្រកប្រហែលជាបីថ្ងៃ យកទៅចាក់ដាក់លើកន្ទេលនោះ ហើយរាបស្រូវឲ្យមានកំរាស់ស្មើគ្នា ទាំងអស់ពេញកន្ទេល ខ្ញុំបាទនៅចាំមើលកុំឲ្យ-មាន់-ទា មកស៊ីមកហួរស្រូវ ហើយខ្ញុំរើស្រូវម្តងៗផង ដើម្បីឲ្យស្ងួតសព្វទាំងអស់ ។

អក្ខរាវិរុទ្ធ.– អាទិត្យ - មេឃ - បរិភោគ - បញ្ចេញ - រាបស្មើ - កញ្ជើ - ជល្រក - រាប - សព្វ ។

## តែងសេចក្តី ១

ចូរអធិប្បាយអំពីការធ្វើអង្ករ តាំងពីហាលស្រូវកិនស្រូវដរាបដល់បានជាអង្ករស (អង្ករសំរិត) តើខ្មែរយើងធ្វើយ៉ាងម្តេចខ្លះ? ការនេះជាការនឿយហត់ច្រើនឬទេ? អ្នកយល់ឃើញដូចម្តេច? ។

ចំនងតែង

សេចក្តីផ្តើម: (វេលាណាដែលគេហាលស្រូវ វេលានោះគេធ្វើដូចម្តេចខ្លះ? ។

– សេចក្តីរៀបរាប់.- គេកិនស្រូវនឹងអ្វី? គេធ្វើយ៉ាងដូចម្តេច? គេជាន់អង្ករនឹងអ្វី? គេអុំ-រែងឬបក់អង្ករនឹងអ្វី? ព្រោះអ្វីបានជាគេអុំ-រែង? ។

– យោបល់របស់អ្នក.– អ្នកយល់ឃើញដូចម្តេច? ការនេះនឿយ

ហាត់ច្រើនឬទេ? គេធ្វើដូចម្តេចវិញ ដើម្បីឲ្យបានឆាយដាន់នេះ ។

## អក្សរផ្ចង់

ង ជ ដ ធ ឯ  ងងុយដេក  ដេងដោង

ជួជក់ដើរផុង  ដកដង្ហើមដេតផត

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ៣.  អំពីថ្នាំ

នាម.— គ្រាប់ថ្នាំ, ផ្លែថ្នាំ, ស្លឹកថ្នាំ, កូនថ្នាំ, ថ្នាល, រមូរស្លឹកថ្នាំ សរសៃថ្នាំ, ជ្រញ់, កាំបិត, ថែប, ខ្សៀ, បារី, ។

គុណនាម.— ខ្លាំង, ខ្សោយ, មូល, ស្ដើង, ក្រាស់, ធ្ងារ, ថ្លោស ស្ងួត, សើម, គ្រប់គ្រាន់, ក្រហមព្រឿង, ស្វាយ ។

កិរិយាសព្ទ.— ព្រោះគ្រាប់ថ្នាំ, ដាំកូនថ្នាំ, បេះស្លឹកថ្នាំ, បន្ទុំថ្នាំ, ហាន់ថ្នាំ, ហាលថ្នាំ, យកសន្សើមថ្នាំ, មូរបារី, ញាត់ខ្សៀ, ជក់បារី, បុកថ្នាំ ។

ហាត់និយាយ.— ថ្នាំជាដំណាំគេដាំយកអ្វី? ដើម្បីនឹងដាំថ្នាំគេធ្វើ-

ដូចម្ដេច? ពេលណាដែលគេដកកូនថ្នាំពីថ្នាលយកទៅដាំក្នុងចំការ? គេដាំថ្នាំចម្ងាយពីគ្នាប្រហែលប៉ុន្មានសង់ទីម៉ែត្រ? ដាំរួចហើយគេធ្វើដូចម្ដេចទៀត? កាលណាដែលគេបេះស្លឹកថ្នាំ? គេបេះស្លឹកថ្នាំយកទៅធ្វើដូចម្ដេចខ្លះ ដើម្បីនឹងមួរជាបារីបាន? គេហាន់ថ្នាំនឹងអ្វី? (សុំឲ្យគ្រូជ្រញ៉ប់បង្ហាញសិស្ស) ។ ហាន់ថ្នាំរួចហើយគេធ្វើដូចម្ដេចទៀត ។

## បង្រៀនមើល

សៀវភៅដែលទំព័រ ១៣៩ តាំងពីគេបេះស្លឹកថ្នាំហើយគេយកមករុំជារមូរបន្ទុំទុកក្នុងម្លប់ ... រហូតដល់ ... គេដាំថ្នាំមិនបានចំនួនគ្រប់គ្រាន់អាស្រ័យទេ ។

ពន្យល់ពាក្យ.– ថែប = ន. ផែនធ្វើពីឬស្សី,បបុសឬស្លឹកត្នោត,ស្លឹកចាកជាដើមសំរាប់ហាលថ្នាំ ។

ថែប = កិ. ប៉ះដែកល្អនឹងដែកអន់ដើម្បីឲ្យមុត ។

ថែប = ន. ដែកអាសេ្យ ឬដែកអាសៀក, ដែកថែប ។

# សរសេរតាមសូត្រ

## អំពីការធ្វើថ្នាំ

គេដាំថ្នាំគ្រប់តែកន្លែងនៅក្នុងប្រទេសឥណ្ឌូចិន ។ ថ្នាំជារុក្ខជាតិមានកំពស់ដល់មួយម៉ែត្រកន្លះ ស្លឹកធំផ្កាពណ៌ក្រហមព្រឿងៗ ឬស្វាយ ផ្លែក្តោបមានគ្រាប់តូចៗនៅខាងក្នុង ។ គេបេះស្លឹកថ្នាំហើយយកបន្ទុំទុកក្នុងម្លប់រួចបូតយកទ្រនុងចេញទើបហាន់ជាសរសៃ ឯហាន់នោះគេហាន់នឹងជ្រញ់សម្រាប់ហាន់ថ្នាំ ។ គេដាក់រមូរស្លឹកថ្នាំក្នុងប្រហោងជ្រញ់ ហើយគេរុញបន្តិចៗទៅមុខ ។

សរសៃថ្នាំដែលគេហាន់យ៉ាងដូច្នេះហើយ ត្រូវយកទៅដផុះហាលលើថែប ថែបនោះគេធ្វើនឹងឬស្សីឬនឹងចបុស គេហាលថ្ងៃហាលសន្សើមបានពីរឬបីថ្ងៃ ថ្នាំនោះស្ងួតហើយមានពណ៌ក្រហមព្រឿងៗ ។

ថ្នាំសម្រាប់ជក់ឬបុក គេជក់ថ្នាំនឹងខ្សៀឬមូរជាបារីតូចៗ ។

## តែងសេចក្តី

ចូរអធិប្បាយអំពីការធ្វើថ្នាំ ដែលអ្នកបានឃើញឬបានឮគេនិយាយ តើការនោះគេធ្វើដូចម្តេចខ្លះ? តាំងពីដាំថ្នាំឡើងរហូតដល់បេះស្លឹកហាន់

បានជាសរសៃរួចហាលបត់បានជាចៅប្តុបាញ់ថ្នាំស្រេច? អ្នកយល់ឃើញថាគួរដាំថ្នាំឲ្យបានច្រើនឬទេនៅស្រុកយើង? ។

## ទំនង់តែង

– សេចក្តីផ្តើម.– (នៅភូមិអ្នកមានគេដាំថ្នាំឬទេ? វេលាណាដែលគេព្រោះគ្រាប់ថ្នាំ គេធ្វើដូចម្តេច?) ។

– សេចក្តីរៀបរាប់.– គេដកកូនថ្នាំទៅដាំក្នុងចំការ (គេធ្វើដូចម្តេចខ្លះ?) ការថែទាំកូនថ្នាំ (គេធ្វើដូចម្តេចខ្លះ?) គេបេះស្លឹកថ្នាំយ៉ាងណា ហើយគេយកស្លឹកនោះទៅធ្វើដូចម្តេច? ការហាន់និងហាលថ្នាំ (គេធ្វើដូចម្តេច?) គេយកសរសៃថ្នាំមកធ្វើដូចម្តេច? ។

– សេចក្តីបញ្ចប់.– អ្នកយល់ឃើញដូចអំពីការធ្វើថ្នាំ? ។

**អក្សរផ្ចង់**

ង ដ ជ ឌ ឯ កុំដឹកដាក

កុំដេកទាល់ថ្ងៃ កុំជក់បារីក្នុងមុង

# កុមារដ្ឋាន

## បង្រៀនពាក្យ - នឹងភាសា

### អាទិត្យទី ១.

### អំពីក្រុមញាតិ

*នាម ៈ– វង្សត្រកូល, ពូជ, ញាតិ, ( ដំណមនុស្សត ៗ ដោយឈាមជាមួយ) សាខា (មែក) សាខាញាតិ, ញាតិ ៧ សន្តាន (ញាតិ-៧ ជួរ) ញាតិពន្ធ (ញាតិមិនតគ្នាដោយឈាមជាមួយ) ញាតិជិត, ញាតិឆ្ងាយ, ញាតិក្នុងស្រុក ៗ*

*គុណនាម.– ខ្ពស់, ទាប, ថោក-ថ្លៃ, មាន-ក្រ, រហេមរហាម, គោកយ៉ាក, ដាបដាប, ទិលខូច, ៗ*

*កិរិយា – ទំនុកបំរុង, ការពារ, គោរព, បង់កេ្ដិ៍, រក្សាកេ្ដិ៍, ដៀលត្មះ ៗ*

*ហាត់ភាសា. គេហៅថាអ្វី ដំណមនុស្សដែលកើតតៗមក? មនុស្សយ៉ាងដូចម្ដេចដែលសំដីត្មះហៅថាមនុស្សឥតត្រកូល? (មនុស្សទិលខូច)*

ដែលហៅមនុស្សមានត្រកូល? (មនុស្សមានបុកខ្ពស់) ។ ញាតិទាំងឡាយមានប៉ុន្មានជំពូក? (ពីរជំពូកគឺញាតិជិតនិងញាតិឆ្ងាយឬសាខាញាតិ) ។ ញាតិពន្ធនោះគឺញាតិយ៉ាងដូចម្តេច? (គឺជាញាតិខាងប្តីនិងខាងប្រពន្ធ) ។

## អាទិត្យទី ២.– អំពីក្រុមញាតិ (ត)

នាម.– ឪពុក (បិតា) ម្តាយ (មាតា) កូនប្រុសកូនស្រី, បងប្អូន, អាយុ, ។

គុណនាម.– ធំ, តូច, ក្មេង, ចាស់, លីវ, ជំទង់, ច្រើន ។

កិរិយា.– បង្កើត, ចិញ្ចឹម, ថែទាំ, ស្រឡាញ់ កោតខ្លាច, ។

ភាសា.– ក្នុងក្រុមញាតិអ្នកមានអ្នកណាខ្លះ? ឪពុកម្តាយអ្នកមានកូនប៉ុន្មាន? អ្នកណាខ្លះ? បងប្រុសអ្នកអាយុប៉ុន្មាន? គាត់មានប្រពន្ធហើយ ឬ នៅលីវ? កូនប្រុសស្រីត្រូវធ្វើម្តេចនឹងឪពុក ម្តាយ? បងប្អូនប្រុសស្រីត្រូវធ្វើម្តេចនឹងគ្នា ។

## អាទិត្យទី ៣.– អំពីក្រុមញាតិ (ត)

នាម.– ជីតា-ជីដូន, ឪពុកធំ, ម្តាយធំ, មា, មីង, បងប្អូនជីដូនមួយ, បងប្អូនជីទួតមួយ, ចៅ, ក្មួយ, ក្មួយជីដូនមួយ, ។

គុណនាម – ចាស់, ជរា, អនិច្ចកម្ម, រស់, ស្លាប់, ញ័រ (ដៃ) កោង (ខ្នង) ។

កិរិយា.– ឈ្លោះប្រកែក, គោរពប្រតិបត្តិ, ទំនុកបំរុង ស្តាប់-បង្គាប់, ទូន្មាន, និយាយរឿង ។

ភាសា.– ជីតាអ្នកអាយុប៉ុន្មាន ? ជីដូនអ្នកនៅរស់ ឬ អនិច្ចកម្មហើយ គាត់ដើរទៅណាឆ្ងាយបានឬទេ ? ពីព្រោះអ្វី ? ជើងដៃគាត់ដូចម្តេច ? អ្នកមានឪពុកម្តាយធំឬទេ ? គាត់នៅឯណា ? គាត់រកស៊ីធ្វើអ្វី ? គាត់មានកូនប្រុសស្រីប៉ុន្មាន ? មាអ្នកត្រូវជាម្តេចនឹងឪពុកអ្នក ? ដូចម្តេចដែលហៅថាបងប្អូនជីដូនមួយ ? បងប្អូនជីដូនអ្នកត្រូវជាម្តេចនឹងឪពុកម្តាយអ្នក ហេតុអ្វីបានជាត្រូវគោរពប្រតិបត្តិជីដូនជីតា ? ដើម្បីឲ្យឪពុកម្តាយសប្បាយចិត្ត អ្នកត្រូវធ្វើដូចម្តេច ? ។

## អាទិត្យទី ៤.– អំពីក្រុមញាតិ (ត)

នាម.– ឪពុកក្មេក, ម្តាយក្មេក, បងថ្លៃ, ប្អូនថ្លៃ, កូនប្រសា ក្មួយប្រសា

គុណនាម – កាច, ស្លូត, ល្អ, អាក្រក់, សុខសប្បាយ, ឈឺ ។

កិរិយា.– និយាយគួរសម, និយាយលេង, រាប់អាន, ជួយគ្នា, ដោះទុក្ខគ្នា, ប្រកាន់ទោស, ធ្ងើងកក្រើន ។

ភាសា.– (សុំតែងពាក្យចោទសួរសិស្សតាមរឿងផង ។

## រៀនមើល-សរសេរ

អាទិត្យទី ១.–

ក្រុមញាតិចៅកេត

សៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ៩៥, ៩៦,

អាទិត្យទី ២.– បងប្អូនចៅកេត

វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៧)

អាទិត្យទី ៣.– ស្រឡាញ់បងប្អូន

វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៩)

អាទិត្យទី ៤.– ត្រូវស្រឡាញ់កោតខ្លាចជីដូនជីតា

ជីដូនជីតាយើងគាត់នឿយព្រួយលំបាកនឹងចិញ្ចឹមឪពុកម្តាយយើង ដូចជាមាតាបិតាយើងនឿយហត់នឹងរកចិញ្ចឹមយើងដែរ ហើយមួយទៀតជីដូនជីតាយើងគាត់ថែទាំរក្សាយើងទៀតផង វេលាដែលឪពុកម្តាយយើងមិននៅ

ទៅធ្វើការ ; ហេតុនេះយើងត្រូវស្រឡាញ់ដីដូនជីតាយើង ដូចជាយើងស្នេហាមាតាបិតាយើងដែរ ។

# បរិច្ឆេទខ្លួន

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១.– នេសាទត្រី

នាម.– នេសាទ, ព្រាន (អ្នកធ្វើរបរនឹងចាប់សត្វព្រៃ ឬសត្វទឹកយកមកចិញ្ចឹមជីវិត ហៅថានេសាទឬព្រាន), ព្រានសន្ទូច, ព្រានសំណាញ់, ព្រានឆ្នុក, ព្រានសំពស់, ព្រានមង, អួន, អញ្ចង,

គុណនាម.– អ្នកនេសាទស្ទាក់, ឆ្នែង, ការនេសាទបរិបូណ៌, ប្រសើរ, មាំមួន, រប៉ិចរប៉ុ, ។

កិរិយា.– នេសាទត្រី, ដកអួន, បង់សំណាញ់, ពាក់មង, អូសអញ្ចង, កៀរត្រី, រាយអួន, ហាលត្រី, ប្រឡាក់ត្រី

ភាសា.– កន្លែងនេសាទធំ ៗ មាននៅកន្លែងណា? (ទន្លេ, បឹងទន្លេសាប, ឈូងសមុទនៅកំពត) មនុស្សជាតិអ្វីដែលធ្វើជារបរនេសាទដ៏ធំៗ (យួន ចាម) ។

## ពាក្យដែលត្រូវបង្រៀនតទៅទៀតក្នុងអាទិត្យជម្រុង

នាម. – នេសាទុបករណ៍ (គ្រឿងប្រដាប់ សំរាប់នេសាទ) ថ្នង, ឈ្នក់, លប, ជន, ទ្រូ, ប្ញុក, ស្ទូ, សន្ទូច, ព្រួល, លាន, ឈ្នាង, អង្រុត, គន, សំណាញ់ ។

គុណនាម.- ធ្ងន់មាំ, សម្រាស់ញឹក, ប្ញុកស្រួប អួនវែង ។

កិរិយា.– លាមង, រាយអួន, លើកជន, ដងត្រី, ទ្រាប, ដាក់ទ្រូ, ពួយប្ញុក, សត្រី, ទស់សម្រាស់, ត្រាំឈ្នាង, ដឹកគន, ក្រុងត្រី, រុត, អញ្ញាត់, ប៉ាប ។

### រៀនមើល

### ១.- អំពីនេសាទត្រី

(សៀវភៅខេមរ. បរិ. ទំព័រ ៨៧)

ពន្យល់ពាក្យ. នុយ= ដុំសាច់ ឬប្រហុក ដែលគេបិតនៅផ្លែសន្ទូច

កំស្ទួល= ដុំ ឈើ ឬស្នោ បង្ហាប់ទឹងខ្សែសន្ទូច ដើម្បីឲ្យសន្ទូចអណ្ដែត ។

ពាក្យខុស= ត្រីរស់ ឲ្យសរសេរត្រីរ៉ស់ ។ អាស្រែ ឲ្យសរសេរ អាស្រ័យ ។

## ២-. អំពីពេលអាស្រ័យបាយឆ្ងាញ់

(សៀវភៅដដែលទំព័រ៤៥)

ពាក្យសរសេរខុស- អាស្រែយ សម្ងរ ស្ងួគ ដោយសា ត្រូវសរសេរ-អាស្រ័យ សម្ល ស្ងួត ដោយសារ ។

### សរសេរតាមសូត្រ

សុំឲ្យយករឿងមើលមកធ្វើដូចប្រក្រតី,ប៉ុន្តែសុំកុំភ្លេចនឹងបង្ហឹកសិស្សឲ្យសរសេរពាក្យពិបាកជាមុននៅក្ដារខៀន ដូចពាក្យ: នេសាទ សន្ទូច ដើរកញ្ច្រែង បោះ លិច រាត់ អាស្រ័យ ។

### បង្រៀនពាក្យនិងភាសា

អាទិត្យទី ២.-

#### ផលនៃនេសាទ

នាម.- ត្រី, បង្កង, អណ្ដើក ,កន្ធាយ, បបែល, អន្ទង់, លៀស, គ្រំ, ខ្យង, ។ ត្រីប្រា, ត្រីព្រួល, ត្រីគល់រាំង, ត្រីត្រសក់, ត្រីព្រលូង, ត្រីរ៉ស់, ត្រីឆ្ដោ, ត្រីបង្វា, ត្រីកែស, ត្រីក្រពាត់, ត្រីឆ្ពាំង, ត្រីពោ, ឆ្លាម ។

គុណនាម.– ត្រីព្រលូងពុល, ថ្លាមកាច, ត្រីគល់រាំងធំ, ស្បែកប-បែលគគ្រាត, ខ្លាញ់ខាប់, ត្រីឆ្អើរក្រៀម, បង្កងស្រស់, ត្រីងៀតស្អិត ។

កិរិយា.– ធ្វើត្រី, វះពោះ, ស្រកា, ប្រៀកងៀត, ប្រឡាក់អំបិល, ហាល, ឆ្អើរ, រំងាស់, ចំហៀរ, លក់, បញ្ជូន, ថ្លឹង ។

## រៀនមើល

១).– ការប្រយោជន៍ដល់អ្នកតាំងពួង

(សៀវភៅខេមរភាសាទំព័រ ១០)

ពាក្យសរសេរខុសក្នុងសៀវភៅត្រូវកែជា: កំហោរ, សូត្រ, មិនដោយសារ, នាយក, ត្រួតត្រា, ពាក្យ, ពោធ.

## សរសេរតាមសូត្រ

(សុំឲ្យធ្វើដូចប្រក្រតី គឺយករៀនមើលមកធ្វើ)

## បង្រៀនពាក្យនិងភាសា

អាទិត្យទី ៣ និងទី ៤.– អាហារកើតឡើងអំពីផលនៃនេសាទ

នាម.– ងៀត ឆ្អើរ ប្រហុក ប្អក កាពិ ទឹកត្រី បង្គា ម្ហូប ។

គុណនាម.– ងៀតក្រៀម ត្រីឆ្អើរស្វិត ស្រួយ ប្រហុកខ្ទោះ ឈ្ងុយ ប្អកជូរ, ខុល, កាពិប្រៃ, ទឹកត្រីឈ្ងុយ, ថ្លា, គ្រឿង ។

កិរិយា.– ឆ្អើរត្រី, ឆ្អើប្រហុក, ចាវប្អក, រំងាស់ទឹកត្រី, ប្រោះស្ល, ចៀន, ចំអិន, បរិភោគ ។

## រៀនមើល

### បិដ្ឋិជ្ឈិកសត្វ – ត្រី

(វត្ថុស្វាធ្យាយន៍ ទំព័រ ៣៨)

ពាក្យខុសក្នុងសៀវភៅត្រូវកែ=ស្រមុទ្រជាសមុទ្រ ឬសមុទ្ទ ។

---

មជ្ឈិមដ្ឋាន ទី ១

## នព្វន្ត

អាទិត្យទី ១.– ១ អំពីលេខគុណចំនួនទសភាគ

ក) លេខតាំងជាចំនួនទសភាគ

ឧបមា.– ចេកមួយស្និតថ្លៃ ២រ,៣៧ តើចេក ៣ ស្និត ថ្លៃប៉ុន្មាន ?

របៀបពន្យល់.– រូបិយវត្ថុឲ្យសិស្សរាប់ ចូរឯងរាប់រូបិយវត្ថុឲ្យ ត្រូវគុណចេក ១ ស្និត (២រ,៣៧) ចុះ ២រ,៣៧ ដែលជាថ្លៃចេក ១ ស្និត ថ្លៃចេក ១ ស្និតត្រូវមាន ២រ,៣៧ ប៉ុន្មានដង ចុះចេកដល់ទៅ ៣ ស្និត ត្រូវជា ២រ,៣៧ ប៉ុន្មានដង ? (៣ ដង) ចូរសរសេរ ២រ,៣៧ បីដង នៅលើក្តារខៀន ?

សេចក្តីរំលឹកសិស្ស.- ត្រូវឲ្យប្រយ័ត្ន ថា ៣ ជាចំនួនគត់ ហេតុនេះត្រូវសរសេរលេខ ៣ ក្រោមលេខ ២ ដែលជាចំនួនគត់ដូចគ្នា ?

របៀបធ្វើលេខ: គឺធ្វើដូចជាគុណចំនួនគត់នឹងគត់ដូចគ្នា គឺ គុណពីស្តាំមកឆ្វេង ៣×៧=២១ សរសេរ១ត្រាទុក២ ៣×៣=៩×២= ១១ សរសេរលេខ ១ ត្រាទុក ១ ៣×២=៦×១=៧ សរុប ៧១១ ក្នុងលេខតាំងមានលេខទសភាគ ២ ខ្ទង់ (៣ និង ៧) ហេតុនេះត្រូវរាប់ ២ ខ្ទង់ ពីខាងស្តាំមកឆ្វេង (ដល់សរុប) ហើយដាក់កណ្តុកសញ្ញា ត្រង់លេខ ២ ដែលជាខ្ទង់គត់ ? ត្រូវរំលឹកសិស្សថា បើចំណែកទសភាគ មានលេខ ៣ ខ្ទង់ ត្រូវរាប់ ៣ ខ្ទង់ពីស្តាំមកឆ្វេង ហើយដាក់កណ្តុកសញ្ញា ( ល ) ?

ការហាត់លើក្តារខៀនៈ សុំឲ្យសិស្សធ្វើបានច្រើន

ក)១៣ល ១៧×៥= ២៧គ.ក ០៥៩×១៣= ១០៧ម ១៦៨×២១៦=

បំណោទងាយ ៗ= ខ្សែមួយកំណាត់ប្រវែង ១ម២៥ ចុះបើ ខ្សែ ៧ កំណាត់ប្រវែងប៉ុន្មាន ៗ

ខ្មៅដៃមួយថ្លៃ ២រ១៥ ចុះបើខ្មៅដៃ ១ ឡូ (១២) ថ្លៃប៉ុន្មាន ៗល ៗ

ការហាត់សរសេរៈ សុំលោកគ្រូលៃលកជ្រើសរើសដាក់ឲ្យ សិស្សធ្វើផងចុះ ៗ

## អាទិត្យទី២– លេខគុណចំនួនទសភាគ (ត)

លេខតាំង ២ សឹងតែចំនួនទសភាគទាំងអស់

បំណោទផ្ដើមៈ ស្រីម្នាក់ទិញទេសឯកខ្មៅ ៣ម៤០ ថ្លៃ ក្នុង ១ម ១៦រ៣៥ តើស្រីនោះបំណាយអស់ប៉ុន្មាន ៗ

របៀបពន្យល់ៈ របៀបពន្យល់បំណោទសុំធ្វើដូចមុន ប៉ុន្តែដល់ ឲ្យធ្វើលេខសុំរំលឹកសិស្សឲ្យប្រយ័ត្នត្រង់ខ្ទង់កណ្ដក់ស័ញ្ញា ពេលដែលឲ្យ រៀបលេខទឹងធ្វើ ត្រូវប្រយ័ត្នឲ្យដាសរសេរលេខត្រង់ជួរពីលើមកក្រោម ខ្ទង់ទសភាគ ៗ លុះដល់ធ្វើលេខរួចហើយ គេរាប់ចំនួនទសភាគដែល មាននៅក្នុងលេខតាំងពីររួចរាប់លេខក្នុងផលរួមមកពីស្ដាំមកឆ្វេង ហើយ ដាក់កណ្ដកសញ្ញា ៗ

ឧបមា: ចម្លើយចំណោទខាងលើនេះ ដល់រួមមកគឺ ៥៧២២៥ ក្នុងលទ្ធផលទាំងពីរមានលេខទសភាគ ៣ ខ្ទង់ (លុបសូន្យចោល) ឲ្យរាប់ពីស្តាំមកឆ្វេងចាប់ពីលេខ ៥ មក ដូចនេះត្រូវដាក់កណ្តកសញ្ញាខាងស្តាំលេខ ៧ ហើយថាស្ត្រីនោះចំណាយអស់ ៥៧៛,២២៥ ឬ ៥៧,២៥ ។

ការបញ្ជាក់លើការផ្ទួន. សុំឲ្យសិស្សធ្វើឲ្យបានច្រើន

៨៣៛៧២×២០,៤= ៩៥ល៣៤×៥.២៦= ១០៩គ.ក០៧៦×៣, ១២៥= ។

ហាត់សរសេរ: ចំណោទ– ដើម្បីនឹងដេរអាវទ្រនាប់ ២ មនុស្សម្នាក់ ទិញទេសឯកស ៣ម១៥ ថ្លៃក្នុង ១ ម៉ែត្រ ១៧៛៣៥ ប្រដាប់ប្រដាផ្សេង ៗ (ខ្សែ អម្បោះ) អស់ ៨៛៥០ ឈ្នួលជាងដេរក្នុងអាវមួយអស់ ២៣៛៨០- តើអ្នកនេះចំណាយទៅក្នុងអាវទ្រនាប់មួយអស់ប៉ុន្មាន ។

អាទិត្យទី ៣.– អំពីលេខសងចំនួនអនិយមភាគ

ចំណោទផ្តើម: ក) រថយន្តមួយចេញពីភ្នំពេញទៅតាខ្មៅ ពីម៉ោង ៨,១៥ មីនុតបើកទៅដល់ដំណាក់ (តាខ្មៅ) នៅពេលម៉ោង- ៩,៣៩ មីនុត តើរថយន្តនោះរថប៉ុន្មានម៉ោងទើបដល់ដំណាក់បត ។

របៀបពន្យល់: សុំលោកគ្រូយកមុខនាឡិកាមកឲ្យសិស្ស

ដាក់ម៉ោងដែលរថយន្តចេញ រួចពេលដែលវាទៅដល់ដំណាក់ ហើយឲ្យរាប់មើល តើរទេះឡានបើកប៉ុន្មានម៉ោងទើបដល់ (១ម,២៤) ចុះនឹងគិតឲ្យឃើញ ១ម,១៤ តើត្រូវធ្វើលេខអ្វី ៗ ឲ្យរៀបលេខធ្វើ ៗ រួចឲ្យកែផាន ៗ

ការហាត់បញ្ជាក់លើក្ដារខៀន : ៦ម៤៩-៤ម,២៣=៩ម៤៨-៦ម= ៣៥= - ១៣ម,៥៣ ១២ម៣២= ( ឲ្យធ្វើឲ្យច្រើន ៗ

រទេះភ្លើងចេញពីពោធិ៍សាត់ នៅពេលម៉ោង ៧,៣៥ ទៅដល់បាត់ដំបងនៅពេលម៉ោង ៨,២៥ តើរទេះភ្លើងនោះបើកប៉ុន្មានម៉ោងទើបដល់បាត់ដំបង ៗ

១) ភ្លៀង ១ មេចាប់ធ្លាក់ពីពេលម៉ោង ២,១៥ ហើយរាំងបាត់ទៅវិញពេលម៉ោង ៣,០៥ តើភ្លៀង ១ មេនោះធ្លាក់ក្នុងប៉ុន្មានម៉ោង ៗ

របៀបពន្យល់ : សុំធ្វើដូចពន្យល់ចំណោទមុន ប៉ុន្តែរបៀបធ្វើលេខខុសគ្នា ៗ

គឺថា: ត្រូវ ៣ម,០៥-២ម១៥=

របៀបធ្វើលេខ : ២ម,៦៥ ប៉ែកខាងខ្ទង់មីនុត ចំនួនធំ

២ម,១៥ គិតជាចំនួនតូច ម,ន

០,៥០ គិតជាង ១៥ម,ន

ហេតុនេះត្រូវដក ១ ម៉ោងពី ៣ ម៉ោង ហើយបំបែកឲ្យទៅជាមីនុតរួចយកទៅបន្ថែមលើខ្ទង់មីនុត ១ម = ៦០ម.ន + ៥ = ម.ន ៦៥ម.ន បើដូចនេះ ៣ម ០៥ ដល់បំបែកទៅត្រូវជា ២ម ៦៥ ទើបធ្វើលេខបាន គឺថា ៦៥ម.ន – ១៥ម.ន = ៥០ម.ន ២ម – ២ម = ០ ។

ឆ្លើយថា: គ្រៀង ១ មេនោះធ្លាក់ក្នុងកំលុង ៥០ មីនុត

**ការហាត់សរសេរ** ចំណោទ មានជើរដើរចេញពីផ្ទះទៅនៅពេលម៉ោង ៧កន្លះ ទៅដល់ពោធិ៍ចិនតុងនៅពេលម៉ោង ១១, ៤២ តើអ្នកនោះដើរប៉ុន្មានម៉ោង ។

## រង្វាស់ . រង្វាល់

### អាទិត្យទី ១. អំពីហ្វ្រង់

**វត្ថុដែលត្រូវយកមកបង្ហាញ** : ផ្ទាំងគំនូររង្វាស់រង្វាល់ ។

**របៀបបង្រៀន**:– បង្ហាញគំនូររូបិយវត្ថុបារាំងនៅក្នុងសៀវភៅ-នព្វន្ត លោក (ឡឹម៉ូអាន) ថ្នាក់អាទិកដ្ឋាននិងមធ្យមដ្ឋានទំព័រ ១៦២–១៦៣–១៦៤–១៦៥ រូបិយវត្ថុប្រធាននៃប្រទេសបារាំងសេសគឺ-ហ្វ្រង់ សរសេរកាត់ (ហ្វ្រ) ១៧ហ្វ្រង់ស្មើនឹងដម្លៃរូបិយវត្ថុយើង ១ រៀលៗ

រូបិយវត្ថុបារាំងមានអ្វីខ្លះ: ១) រូបិយវត្ថុធ្វើអំពីលោហធាតុ ,

ក) អំពីសំរិទ្ធ (bronze) ១សង្ទីម ៥សង្ទីម ១០សង្ទីម

ខ) អំពីកល់មាំង ២៥ សង្ទីម ១០ស ៥ស

គ) អំពីអាលុយមីនីញូម ៥០ស ១ ហ្វ្រង់ ២ ហ្វ្រង់

ឃ) អំពីប្រាក់ ១០ ហ្វ្រង់ ២០ ហ្វ្រង់

ង) អំពីមាស ១០០ ហ្វ្រង់

២) រូបិយវត្ថុធ្វើអំពីក្រដាស= ក្រដាស ៥០-ហ្វ្រង់ ៥០០ ហ្វ្រង់ ១០០០ ហ្វ្រង់

## អាទិត្យទី ២- អំពីដម្លៃនៃរូបិយវត្ថុបារាំង

របៀបបង្រៀន= ហ្វ្រង់មានរូបិយវត្ថុដែលមានតម្លៃតិចជាង ពីរយ៉ាងគឺ ដេស៊ីមនិងសង្ទីម ដេស៊ីមតម្លៃតិចជាងហ្វ្រង់ ១០ ដង ហេតុនេះ ១ ហ្វ្រង់មាន ១០ ដ. សរសេរ ០ ហ្វ្រ ១ ដេស៊ីម សរសេរមួយខ្ទង់ខាងស្តាំហ្វ្រង់ ( ស្តាំកណ្តកសញ្ញា ) ឧបមា ២ ហ្វ្រង់ ៥ ដេស៊ីមសរសេរ ២ ហ្វ្រ ៥ ។

សង្ទីមតម្លៃតិចជាងហ្វ្រង់ ១០០ ដង ហេតុនេះ ១ ហ្វ្រង់មាន ១០០ ស. ០ ហ្វ្រ ០ ១ សង្ទីម សរសេរ ២ ខ្ទង់ខាងស្តាំហ្វ្រង់ ( ស្តាំកណ្តកសញ្ញា ) ឧបមា ៧ ហ្វ្រង់ ៤ សង្ទីម សរសេរ ៧ ហ្វ្រ ០ ៤

ការហាត់បញ្ជាក់= ៤ ហ្វ្រង់មានប៉ុន្មានដេស៊ីម ៗ សង្ទីម ៗ ៧៩ ដេស៊ីមត្រូវជាប៉ុន្មានហ្វ្រង់ ៗ ១៧៨ សង្ទីមត្រូវជាប៉ុន្មានដេស៊ីម ប៉ុន្មានហ្វ្រង់ ៗ ល ៗ

ការហាត់សរសេរ= ចូរធ្វើលេខខាងក្រោមនេះ ៗ

១៣ ហ្វ្រ ៧១ ស + ២៩ ហ្វ្រ ៨ ស + ៣៥ ហ្វ្រ ៩ ដ = .... ដេស៊ីម

២៩៨ ស – ៣ ដ ៩ = ..... ហ្វ្រង់

៦៥ ហ្វ្រ ០៧ + ៣៥ = ..... ដេស៊ីម ឬ ..... សង្ទីម

បំណោទ= សិស្សម្នាក់ធ្វើទិញសៀវភៅមួយពីស្រុកបារាំងថ្លៃ ២៣៧ ហ្វ្រ ៥០ វាត្រូវចេញថ្លៃផ្ញើសៀវភៅ ២៥ ហ្វ្រ ១៥ ប្រៃសនីយ យកពន្ធ ១៣ ហ្វ្រ ៣៥ តើសិស្សម្នាក់នោះចំណាយអស់ប៉ុន្មានរៀល បើរូបិយវត្ថុបារាំង ១៧ ហ្វ្រង់ ស្មើនឹងថ្លៃប្រាក់យើង ១ រៀល ៗ

អាទិត្យទី ៣= អំពីរូបិយវត្ថុស្រុកអាយ (ប្រទេសឥណ្ឌូចិន) របស់ដែលយកមកបង្រៀន= ប្រាក់ ១ រៀល ក្រដាស ១ រៀល គ្រប់យ៉ាង ផាន់ដើមនឹងចេញថ្មី ក្រដាស ៥ រ ក្រដាស ១០ រ, ក្រដាស ២០ រ, (ផាន់-ចាស់នឹងថ្មី) ក្រដាស ៥០ រ ក្រដាស ១០០ រ (ចាស់នឹងថ្មី) ក្រដាស ៥០-សេន ក្រដាស ២០ សេន ក្រដាស ១០ សេន ក្រដាស ៥ សេន ៗ

រូបិយវត្ថុធ្វើអំពីលោហធាតុ= ប្រាក់៥០សេន ប្រាក់២០ស. ប្រាក់១០-ស. លុយ៥សេន លុយ១សេន (បើរកបាន សុំឲ្យយកលុយ២សេននឹង ១សេនមកបង្ហាញឲ្យសិស្សស្គាល់ផង ។

របៀបបង្រៀន= នឹងសងថ្លៃទិញ គេត្រូវការនឹងរូបិយវត្ថុ រូបិយវត្ថុប្រធាន នៅនាប្រទេសឥណ្ឌូចិនគឺរៀល សសេរកាត់ (រ) (បង្ហាញឲ្យមើល) រៀលមានប៉ុន្មានយ៉ាង ។ ហេតុអ្វីបានជាគេធ្វើរូបិយវត្ថុអំពីក្រដាសផង ។ ១រៀលមានថ្លៃស្មើនឹង១៧ហ្វ្រង់បារាំង ។

តម្លៃនៃរូបិយវត្ថុស្រុកអាយ១, រូបិយវត្ថុតម្លៃច្រើនជាង១រៀល ឲ្យសិស្សយកក្រដាសប្រាក់គ្រប់យ៉ាងមករាប់មើល ២,)រូបិយវត្ថុតម្លៃតិចជាង ១រៀល ឲ្យសិស្សរាប់ ។

ការហាត់ឲ្យចេះប្រើប្រាស់= ឲ្យសិស្សដូររូបិយវត្ថុ ប្តូរឯងដូរក្រដាស១០០៛ នេះឲ្យមានក្រដាស៥០៛ខ្លះ ២០៛ខ្លះ ១០៛ខ្លះ ៥៛ខ្លះ ១៛ខ្លះ

ការហាត់លើការជួន= មនុស្សម្នាក់ទិញស្បែកជើង ១ សំរាប់ថ្លៃ ១៩៥៛ ស្រោមជើង១គូរថ្លៃ៣៧៛ អ្នកនោះឲ្យក្រដាស១០០៛ បីសន្លឹកទៅឈ្មួញ តើឈ្មួញថែមក្រដាសប្រាក់អ្វីខ្លះមកវិញ ។

ការហាត់សរសេរ= ដើម្បីនឹងសងថ្លៃទិញ៧០រៀល ខ្ញុំឲ្យក្រដាស៥៛.... សន្លឹកក៏បាន ។ ក្រដាស២០៛........ សន្លឹកនឹងក្រដាស៥៛ .......... សន្លឹកក៏បាន ។

បើសិនណាខំឲ្យក្រដាស១០០៛ទៅឈ្មួញ ។ នោះត្រូវថែមក្រដាស ៥៛......សន្ទឹកមកឲ្យខំវិញ ។ ឬក្រដាស២០៛........សន្ទឹកហើយទឹង ក្រដាស៥៛......សន្ទឹកមកខំវិញក៏បាន ។

## ធរណីមាណសាស្ត្រ

### អាទិត្យទី ១ អំពីត្រីកោណ (ត) ការគិតគូរកផ្ទៃក្រឡា រកបាតនឹងកំពស់ (ការគិតគូរកផ្ទៃក្រឡា

របស់ដៃលគ្រូយកមកបង្រៀន.— សុំយកក្រដាសក្រាស់មួយបន្ទះមកកាត់ជារាង បួនជ្រុងញ្នយស្របមួយ បាតប្រវែង ៨ សង្ទីម៉ែត្រ កំពស់ប្រវែង ៤ សង្ទីម៉ែត្រ ហើយកាត់ត្រីកោណមួយទំហំស្មើនឹងពាក់កណ្ដាលបួនជ្រុងញ្នយស្របខាងលើនេះ ។

របៀបបង្រៀន.— ឲ្យសិស្សវាស់កំពស់ បាតនៃបួនជ្រុងញ្នយស្រប




រួចឲ្យកាត់បត់ចតុរង្សនេះជាពីរតាមកំពូលមុមហើយសួរថា បើគេចែកបួនជ្រុងញ្នយស្របជាពីរ តើចតុរង្សនោះកើត

បានទៅជាអ្វី ៗ ត្រីកោណពីរ ៗ ត្រីកោណទាំងពីរនោះ មានសណ្ឋានយ៉ាងណាៗទំហំស្មើគ្នា ៗ ឲ្យពិនិត្យបានត្រីកោណទាំងពីរ ៗ ស្មើនឹងបាតបួនជ្រុងព្នាយស្រប ៗ រួចឲ្យយកត្រីកោណដែលកាត់ ទៅដាក់ផ្ទាប់ពីលើត្រី-កោណដែលកើតចេញពីបួនជ្រុងព្នាយស្របដែលបត់ ៗ ដូច្នេះត្រីកោណនឹងបួនជ្រុងព្នាយស្របវាយ៉ាងដូចម្ដេចនឹងគ្នា ៗ ត្រីកោណត្រូវជាពាក់កណ្ដាលបួនជ្រុងព្នាយស្រប ៗ ចុះបាត ៗ ប្រវែងស្មើគ្នា ៗ

ហេតុនេះនឹងរកផ្ទៃក្រឡានៃត្រីកោណ គេធ្វើដូចម្ដេច ៗ គុណបាតនឹងពាក់កណ្ដាលកំពស់ $(ប \times \frac{ក}{២})$ ឬពាក់កណ្ដាលបាតនឹងកំពស់ $(\frac{ប}{២} \times ក)$ ឬគុណបាតនឹងកំពស់រួចចែកផល់ជាពីរ $(ប \times \frac{ក}{២}$

ឧបមា·ត្រីកោណមួយបាតប្រវែង ៨ សង្ទីម៉ែត្រ កំពស់ ៤ ស.ម៉ តើត្រីកោណនោះមានផ្ទៃទំហំប៉ុន្មានសង្ទីម៉ែត្រក្រឡា ៗ

របៀបគិតលេខ: ១ បាត ៨ សម គុណនឹងពាក់កណ្ដាលកំពស់ ៤សម៉ ២ សម៉ ត្រូវជា ១៦ សម$^{២}$ ៗ ២,– ពាក់កណ្ដាលបាត $\frac{៨}{២}$ ស.ម ៤ សម គុណនឹងកំពស់ ៤ ស.មត្រូវជា១៦ សម២ ៗ

៣) បាត៨ សមគុណនឹងកំពស់ ៤ សម ត្រូវជា ៣២ សម$^{២}$ ចែកនឹង ២ ត្រូវជា ១៦ សម$^{២}$ ៗ

### ការហាត់ដោយបញ្ញា – សុំធ្វើឲ្យបានច្រើន

ស្រែមួយរាងត្រីកោណបាតប្រវែង ១០ម កំពស់ប្រវែង ៦ម តើទំហំស្រែនោះប៉ុន្មានម៉ែត្រក្រឡា ?

**ការហាត់លើក្តារឆ្នួន**–ដី១ក្បាលរាងជាត្រីកោណ បាតប្រវែង១៥៦ម កំពស់ ៨៤ ម តើទំហំដីនោះមានប៉ុន្មានម៉ែត្រក្រឡា ?

គេទិញស្រែមួយរាងត្រីកោណ បាតប្រវែង ២១៨ម កំពស់ ១០២ម ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៣២ រៀល តើគេចំណាយអស់ប្រាក់ប៉ុន្មានរៀល ?

**ការហាត់សរសេរ**– មនុស្សម្នាក់ទិញដីមួយក្បាលរាងជាត្រីកោណស្មើជ្រុងទាំងបី បាតប្រវែង២៣៤ម កំពស់១២២ម ថ្លៃក្នុង ១ម ២៤រ,៥០ តើធ្វើរបងព័ទ្ធជុំវិញថ្លៃក្នុង ១ ម ១៨រ៧៥ តើអ្នកនោះចំណាយអស់ប្រាក់ប៉ុន្មានរៀល ?

### អាទិត្យទី ២.– ការគិតគួររកបាត

**ឧទាហរណ៍**.– ដីមួយរាងត្រីកោណ ផ្ទៃក្រឡាទំហំ ២៧០ម$^{២}$ កំពស់ប្រវែង ១២ម តើបាតដីនោះប្រវែងប៉ុន្មានម៉ែត្រ ?

**របៀបគិតលេខ**– ចែកផ្ទៃនឹងពាក់កណ្តាលកំពស់ = ផ្ទៃ ២៧០ ម$^{២}$

ចែកនឹងពាក់កណ្តាលកំពស់ $\frac{\text{១២ម}}{\text{២}}$ ៦ម = ៤៥ម

ការហាត់បញ្ជាក់ សុំឲ្យធ្វើឲ្យបានច្រើន–ស្រែ ១ រាងត្រីកោណ ផ្ទៃក្រឡាទំហំ ១២៣០ម៉ កំពស់ ៣១០ម តើបាតចំការនោះប្រវែងប៉ុន្មាន

ការហាត់សរសេរ.– ចំការ ១ នឹងស្រែ ១ ទំហំប៉ុនគ្នា ផ្ទៃក្រ-ឡាមាន ២៤០០ ម៉$^{២}$ ចំការរាងបួនជ្រុងព្នាយស្រប បាតប្រវែង ៤៨ ម៉ កំពស់ ២៥ ម៉ តើបាតស្រែដែលរាងជាត្រីកោណមានប្រវែងប៉ុន្មាន បើកំពស់ប្រវែង ៦០ ម៉ ។

អាទិត្យទី ៣.– ការគិតគូរកំពស់

ឧទាហរណ៍_ សួនមួយរាងត្រីកោណ ទំហំមាន ៩៦០ ម៉$^{២}$ បាតប្រវែង ១២០ ម៉ តើកំពស់សួននោះប្រវែងប៉ុន្មាន ។

របៀបគិតលេខ.– ចែកផ្ទៃក្រឡានឹងពាក់កណ្ដាលបាត ផ្ទៃ ៩៦០ ម$^{២}$ ចែកនឹងពាក់កណ្ដាលបាត $\frac{១២០}{២}$ ម៉ ឬ ៦០ ម៉ ត្រូវជា ១៦ម៉

ការបញ្ជាក់ឲ្យឃើញខុសត្រូវ– រកឲ្យឃើញផ្ទៃក្រឡាឡើងវិញ គឺគុណបាត ១២០ ម៉ នឹងពាក់កណ្ដាលកំពស់ $\frac{១៦}{២}$ ម៉ ឬ ៨ម៉ ត្រូវជា ៩៦០ ម៉$^{២}$

ការហាត់បញ្ជាក់. សុំឲ្យសិស្សធ្វើឲ្យបានច្រើន

ការហាត់សរសេរ.– គេដូរដីបួនជ្រុងទ្រវែង ១ ទីនឹងស្រែ ១ កង ត្រីកោណ ទំហំស្មើគ្នាមាន ២៦៤៦ ម២ បណ្ដោយដីកង់ ៤ ជ្រុងទ្រវែង ៤៩ម ទទឹង ២៧ម បាតស្រែនោះប្រវែង ៥៤ ម តើកំពស់ស្រែនោះប្រវែងប៉ុន្មាន ។

---

# អាជិកដ្ឋាន

## គុណ

មេរៀនទី ១– លេខគុណនឹង ១០. ១០០, ១០០០

សៀវភៅ ១ មាន ១៦ សន្លឹក ។ តើសៀវភៅ ១០ ។ សៀវភៅ ១០០ ។ សៀវភៅ ១០០០ មានប៉ុន្មានសន្លឹក ។

ដើម្បីនឹងរកចំនួនសន្លឹកដែលមាននៅក្នុងសៀវភៅ ១០ សៀវភៅ ១០០ សៀវភៅ ១០០០, ត្រូវយកចំនួនសន្លឹកគុណនឹងសៀវភៅ ១០ ។ ១០០ ។ ១០០០ ។ គឺ.

១៦$^{\text{ស}}$ × ១០= ១៦$^{\text{ស}}$ × ១០០= ១៦$^{\text{ស}}$ × ១០០០=

សេចក្ដីសំខាន់.– ដើម្បីគុណចំនួនណានឹង១០ ។ ១០០ ។១០០០ បើមិនបាច់ធ្វើលេខគុណទេ គេគ្រាន់តែថែមនៅស្ដាំចំនួននោះសូន្យមួយ

បើគុណនឹង១០ ។ សូន្យពីរបើគុណនឹង ១០០ ។ សូន្យបីបើគុណនឹង ១០០០(ល) ។ ១៦×១០=១៦០, ១៦ ១០០=១៦០០, ១៦× ១០០០=១៦០០០,

**វិធីហាត់គិតមាត់ទទេ –** ត្រូវជាប៉ុន្មាន

ផ្លែស្វាយ៣ដប់ដង ។ ផ្លែពុទ្រា៤ដប់ដង ។ ផ្លែដូង២៩ដប់ដង ។ សំពត់ ១ម៉ែត្រថ្លៃ១៩, តើថ្លៃប៉ុន្មានសំពត់១០ម ។ ១០០ម ។ ១០០០ម ។ គោញី១ថ្លៃ២៥០រ តើគោញី ១០០ ថ្លៃប៉ុន្មាន ។ ក្នុងមួយថ្ងៃម្ដាយខ្ញុំសន្សំ ៧៥រ តើក្នុង១០០០ថ្ងៃគាត់សន្សំបានប៉ុន្មានរៀល ។

**វិធីហាត់សរសេរ.–** ១ - ចូរធ្វើលេខខាងក្រោមនេះ

១៦រ×១១= ១៥ល × ១០០=, ៦៣ល ×១០០០=៥ ×=៥០ស

២៥រ×១០=៣៦ល×១០០=; ៤៥ស×១០០០=; ៣៤រ×= ៣៤រ

៧×១០= ៩ល ×១០០= ៥៧ស ×១០០០=; ៨×= ៨០០រ

## មេរៀនទី ២.– លេខគុណចំនួនបែងកាគគត់

១០ – ១០០ – ១០០០ –

ដងប៉ាកកា ១ ថ្លៃ ៣រ៥០ តើដងប៉ាកកា ១០ ១០០ – ១០០០ ថ្លៃប៉ុន្មាន

ដើម្បីនឹងរកថ្លៃដងប៉ាកកា ១០-១០០-១០០០- ត្រូវយកថ្លៃដងប៉ាកកា

មួយគុណនឹងចំនួនដង៏ប៉ុកការ ១០·១០០·១០០០ គឺ ៣៛៥០ ១០= ៣៛៥០ ១០០= ៣៛៥០ ១០០០=

**សេចក្ដីសំខាន់.–** ដើម្បីនឹងគុណរកចំនួនបែងភាគរាយ ១០·១០០ ១០០០ គេត្រូវរំកិលក្បៀសទៅខាងស្ដាំមួយខ្ទង់បើគុណនឹង១០ ពីរខ្ទង់បើគុណនឹង ១០០ បីខ្ទង់បើគុណនឹង ១០០០ ។

ឧបមា ៣៛,៥០ × ១០ = ៣៥៛,០០ ៣៛,៥០ × ១០០ = ៣៥០៛, ៣៛,៥០ ១០០០ = ៣៥០០៛,០០

**វិធីហាត់មាត់ទទេ.–** ត្រូវជាប៉ុន្មាន

គុណនឹង ១០ ៥៛,៦២; ៣០ម,៤; ៥៣ល៨១; ២៥,៧០ ។

គុណនឹង១០០ ៣១៛,៧០; ៤ម,០៨៣; ០ស៩៣៧; ២១ម,០០៦ ។

គុណនឹង១០០០ ០៛,៥៨; ៥ម,៤០៨; ៣ល០០៦; ២៥៛,០៧ ។

សៀវភៅ ១ ថ្លៃ ១៛,៩៥ តើសៀវភៅ ១០០ ថ្លៃប៉ុន្មាន ។

ស្ករមួយគីឡូក្រាមថ្លៃ ១១៛,៨៥ តើ ១០ គីឡូក្រាមថ្លៃប៉ុន្មាន ។

ខ្សែលួសមួយម៉ែត្រថ្លៃ ០៛៩៨ តើ ១០០០ ម៉ែត្រថ្លៃប៉ុន្មាន ។

**វិធីហាត់សរសេរ.–** ចំណោទ

ជាងដេរសំលៀកបំពាក់ម្នាក់ទិញសំពត់ផាឌិបចំនួន ១០០០ ម៉ែត្រ ថ្លៃក្នុង ១ម, ១២៛,០៨ ហើយនឹងសំពត់សាក្លាតចំនួន ១០ម, ថ្លៃ ៨៥៛, ក្នុង

១ ម៉ែត្រ ៗ តើគេត្រូវថែមមកវិញប៉ុន្មាន បើជាងនោះឲ្យក្រដាសប្រាក់ ១០០៛ ចំនួន ៧ សន្លឹកទៅអ្នកលក់សំពត់ ៗ

## មេរៀនទី ៣.— លេខគុណនៃចំនួនបែងភាគគត់

| | | |
|---|---|---|
| ×២៥,៨ | ×២០,៣២ | នឹងធ្វើលេខគុណចំនួនភាគគត់ |
| ៤,១៣ | ២,៤១ | |
| +៧៧៤ | +២០ ៣២ | ទី១— គេសរសេរចំនួនលេខទាំង |
| ២៥៨ | ១០៩៦០ | |
| ១០៣២ | ៤០៦៤ | ពីរនោះ មួយលើមួយក្រោម |
| ១០៦៥,៥៤ | ៤១,០០៣២ | |

ហើយគុណដូចជាចំនួនដុំដែរ ឥតមានការប្រណ៍នឹងកណ្ដុកសញ្ញាឡើយ

២— គេត្រូវដាក់សញ្ញានៅខាងស្ដាំល័ក្ខ តាមចំនួនលេខបែងភាគ ដែលមាននៅក្នុងចំនួនដំណាំងនឹងមេគុណ ៗ

វិធីហាត់មាត់ទទេ.— ខ្សែលួសមួយបន្លាយមាន ១២ម៉ែត្រ៣០ តើខ្សែលួស ៥ បន្លាយមានប៉ុន្មានម៉ែត្រ ៗ

អង្ករមួយកំប៉ុងថ្លៃ ២៛១៥ តើ៤កំប៉ុងថ្លៃប៉ុន្មាន ៗ សំពត់មួយម៉ែត្រថ្លៃ១៣៛២០ តើសំពត់ ៣ម ៥០ ថ្លៃប៉ុន្មាន ៗ

មេ្រ្ទមួយគីឡូក្រាមថ្លៃ ០៛៣៥ តើ ៣ គក្រ ៧៤ ថ្លៃប៉ុន្មាន ៗ

វិធីហាត់សរសេរ,– ចូរធ្វើលេខខាងក្រោមនេះ

២៥៨ × ១៤,៣= ៤៥៧ × ២, ៤៨= ១២០ ៣០ × ១៣.៣០ ៨៨
០៤×២,៤=, ៦៥២ × ០, ៣៥១=, ១២៨៩, ១៣ × ១,៥១៣

បំណោទ,– ជាងអារឈើ ១៨ នាក់ធ្វើការក្នុងរោងអារឈើក្នុង ១ថ្ងៃម្នាក់ៗ បានឈ្នួល០៛,៧៥ ជាងអារទាំងអស់នោះធ្វើការ ៣១២ ថ្ងៃ ក្នុង ១ ឆ្នាំ តើប្រាក់ឈ្នួលជាងអារឈើប៉ុន្មានក្នុង ១ ឆ្នាំ ?

## រង្វាស់រង្វាល់

មេរៀនទី ១– សូមយកផ្ទាំងគំនូររង្វាស់រង្វាល់ដែលមានរូបិយវត្ថុ គឺហ្វ្រង់ សង់ទីម ៗ ល ៗ មកបង្ហាញសិស្សឲ្យឃើញជាក់ច្បាស់ រួចហើយប្រាប់ថានៅប្រទេសយើង គេចាយប្រាក់រៀលៗ ក្នុងនគរនីមួយៗមានប្រាក់សំរាប់ចាយផ្សេងៗពីគ្នា ដូចប្រាក់រៀលចាយសព្វថ្ងៃនេះ មិនមែនដូចប្រាក់ដែលគេចាយនៅនគរសៀមទេ ។ ឯចំណែកនៅស្រុកបារាំងសែសនឹងចេញឲ្យថ្លៃទំនិញដែលគេទិញនោះត្រូវឲ្យជាហ្វ្រង់ ៗ ហ្វ្រង់នេះគឺមេរូបិយវត្ថុនៅនគរបារាំងសែស គេសរសេរកាត់ហ្វ្រ ។ បួនណាមានមនុស្សនៅនគរយើងនេះទិញទំនិញនៅស្រុកបារាំងសែស មនុស្សនោះត្រូវចេញថ្លៃជាចំនួនហ្វ្រង់ ដើម្បីឲ្យបានប្រាក់ហ្វ្រង់នោះ គេត្រូវប្តូរប្រាក់រៀលយើង

នឹងប្រាក់ហ្វ្រង់ សព្វថ្ងៃនេះកាលណាគេយកប្រាក់ ១ រៀលទៅ គេដូរបានជា ១៧ ហ្វ្រង់ ហេតុនេះគេដឹងថាក្នុង ១ រៀល យើងមានថ្លៃ ១៧ ហ្វ្រង់ ។ ឯការប្តូរគ្នាបានតែនៅផ្ទះចងការប្រាក់ ឬនៅផ្ទះខ្សែលួស បើគេផ្ញើទៅទិញទំនិញនៅស្រុកបារាំងសែស កាតរយពីហ្វ្រង់ គឺសន្ទីម នៅក្នុងចំនួនហ្វ្រង់សន្ទីម ត្រូវសរសេរនៅខ្ទង់ទី២ខាងស្តាំកណ្តក់ស័ញ្ញា ។

វិធីហាត់គិតមាត់ទទេ.– កន្លះហ្វ្រង់ត្រូវជាប៉ុន្មានសន្ទីម ។ មួយហ្វ្រង់ត្រូវជាប៉ុន្មានសន្ទីម ។ ៣ ហ្វ្រង់កន្លះត្រូវជាប៉ុន្មានសន្ទីម ។ ១២ ហ្វ្រង់ត្រូវជាប៉ុន្មានសន្ទីម ។ល។ ១០០ សន្ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ៤០០ សន្ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ៦៧០ សន្ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ថ្លៃប្រាក់រៀលគឺ ១៧ ហ្វ្រង់ ប្តូរគិតជាហ្វ្រង់ត្រូវបានប៉ុន្មាន បើប្រាក់ ៦៛ ។ ៨៛ ។ ១៣៛ ។ ៥០៛ ។ល។ ថ្លៃប្រាក់រៀល គឺ ១៧ ហ្វ្រង់ ត្រូវបានប៉ុន្មាន បើ ២០ ហ្វ្រង់ ។ ១៥ ហ្វ្រង់ ។ ៦៧ ហ្វ្រង់ ។ ៤៥ ហ្វ្រង់ ។ ៣២០ ហ្វ្រង់ ។ ៤៨០ ហ្វ្រង់ ។

បំណោទ.– ១– នៅផ្ទះលក់សៀវភៅមួយ គេទិញសៀវភៅមើល ២ ថ្លៃ ៨ ហ្វ្រង់មួយនិងសៀវភៅមើលមួយទៀត ថ្លៃ ១៨ ហ្វ្រង់ បើថ្លៃប្រាក់រៀល ២០ ហ្វ្រង់ ខ្ញុំត្រូវឲ្យប៉ុន្មានរៀលទៅអ្នកលក់សៀវភៅ

នោះ ។ ២) ក្នុងហាងផាំងមួយមានគ្រែឈើមួយគេដាក់ថ្លៃ ៧០ គ្រែដេកមួយ ១៨០០ ហ្វ្រង់ ដម្លៃប្រាក់ ១៧ ហ្វ្រង់ តើគ្រែណាថ្លៃជាងគេ ។

មេរៀនទី ២.– រៀនសាអំពីរង្វាស់បណ្ដោយ ម៉ែត្រនិងដេកាម៉ែត្រ សូមតែងធ្វើឲ្យគ្រប់សេចក្ដីផ្សេងៗដូចខែមុនៗមក ។

មេរៀនទី ៣.– រៀនសាពីហិកតូម៉ែត្រនិងគីឡូម៉ែត្រ ។

មេរៀនទី ៤.– រៀនសាអំពីដេស៊ីម៉ែត្រ សង់ទីម៉ែត្រ មិលីម៉ែត្រ ។

---

## កុមារដ្ឋាន

### គណិត

ក្នុងខែនេះគ្រូបង្រៀនសិស្សឲ្យចេះរាប់ ចេះអាន ចេះសរសេរ ចំនួនពី៨០ដល់១០០ ឲ្យចេះធ្វើលេខបូកនឹងលេខបង្កមានត្រាទុក ចេះគុណនឹងចែកចំនួននឹង៤ ។

មេរៀនទី១ --រៀនរាប់·រៀនអានរៀនសរសេរចំនួនពី៨០ដល់៩០ ។

របស់សំរាប់បង្រៀន –ចង្កឹះបាច់៨បាច់នឹងចង្កឹះរាយ១០ឬប្រាក់កាក់១០សេន៨នឹងលុយសេន១០ ។

របៀបបង្រៀន ១. មតិសំខ្យា.–ឲ្យសិស្សរាប់បន្ថែម ពីរៗ បីៗ បួនៗ ពី១ដល់៨០ រាប់បន្ថយពី៨០មក១វិញ ៗ

២.–ផ្សំចំនួនពី៨០ដល់៩០..លើកបង្កើះ៨បាច់បង្ហាញសិស្ស ហើយសួរថានេះបង្កើះប៉ុន្មាន ៗ ៨០ថែមបង្កើះ១ទៀតត្រូវជាប៉ុន្មាន ៗ គ្រូសរសេរចំនួន៨១នៅលើក្ដារខៀន ហើយពន្យល់របៀបសរសេរចំនួននោះ (លេខ៨នៅខ្ទង់ដប់-លេខ១នៅខ្ទង់រាយ)ឲ្យសិស្សអានចំនួននោះ ហើយឲ្យសរសេរនៅលើក្ដារឆ្នួន ៗ ធ្វើតាមរបៀបនេះរហូតដល់ចំនួន៩០ ៗ

៣. ការហាត់អានចំនួន.–គ្រូបង្អុលចំនួនដែលសរសេរនៅលើក្ដារខៀនឲ្យសិស្ស ឬថាចំនួនឲ្យសិស្សបង្អុល ឬឲ្យសិស្សម្នាក់ថាចំនួន ឲ្យសិស្សឯទៀតបង្អុល ឬឲ្យសិស្សម្នាក់បង្អុលឲ្យសិស្សឯទៀតថា ៗ

៤-ការរៀនសរសេរចំនួន–គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន ៗ

៥–ការហាត់មាត់ទទេ.– លេខប៉ុន្មាននៅខ្ទង់ដប់- លេខប៉ុន្មាននៅខ្ទង់រាយក្នុងចំនួនប៉ែតសិបបី- ប៉ែតសិបប្រាំ ប៉ែតសិបប្រាំពីរ - ប៉ែតសិបប្រាំបី ៗ ល ៗ

៦-ការហាត់សរសេរនៅក្នុងសៀវភៅ.-

ចំណាំ.–នៅក្នុងទូមានសៀវភៅមើល៨៧ ៗ លោកគ្រូយកមក

ចែកសិស្សម្ដងអស់៣៥ ម្ដងទៀតអស់២០ ។ លោកគ្រូចែកទាំងពីរលើក អស់សៀវភៅ.....ត្រូវនៅសល់សៀវភៅ.....ក្នុងទូ ។

មេរៀនទី២.–ចំនួនដល់៩០.លេខបូកមានត្រាទុក ។

របស់សំរាប់បង្រៀន.–ចង្កឹះបាច់ ចង្កឹះរាយ ប្រាក់កាក់ដប់សេន និងលុយសេន ។

របៀបបង្រៀន.– ១.មតិសំខ្យា.– ឲ្យសិស្សរាប់ចង្កឹះឬលុយ បន្ថែមពីរៗបីៗបួនៗ ពីមួយដល់៩០ ។

២– ពន្យល់របៀបធ្វើលេខបូកមានត្រាទុក .– ឲ្យសិស្សម្នាក់កាន់ ប្រាក់កាក់៤ នឹងសេន៥(៤៥សេន) សិស្សម្នាក់ទៀតកាន់ប្រាក់កាក់៣ នឹង សេន៧(៣៧សេន) តើសិស្សទាំងពីរនាក់មានលុយប៉ុន្មានសេន ។ គ្រូ តាំងលេខបូក + ៤៥ស / ៣៧ស នៅលើក្ដារខៀនហើយនាំសិស្សធ្វើលេខបូកនោះ (៥ស នឹង ៧ស ត្រូវជា ១២ស ចំនួននេះលើសពី ៩ គេត្រូវសរសេរចំនួន រាយ២នៅក្រោមចំនួនរាយ ហើយត្រាចំនួនខ្ទង់ដប់ទុកយកទៅបូកនឹងខ្ទង់ ដប់ ១ នឹង ៤ ត្រូវជា ៥ ។ ៥នឹង៣ត្រូវជា៨ ទាំងអស់ត្រូវជា៨២សេន) ។

៣– ការហាត់បញ្ជាក់នៅលើក្ដារខៀន.–ឲ្យសិស្សធ្វើលេខបូកមាន ត្រាទុកនៅលើក្ដារខៀន៖ ២៧ស+៣៦ស= ។ ៣៩ស+៤៣ស= ។ ៥៤ស+២៧ស= ។

៤– ការហាត់បញ្ជាក់នៅលើក្ដារខៀន –ឲ្យសិស្សធ្វើលេខបូកមានត្រាទុកនៅលើក្ដារខៀន របៀបដូចខាងលើនេះ ។

៥–ការហាត់សរសេរនៅក្នុងសៀវភៅ

| | | | |
|---|---|---|---|
| + ៣៤ស | + ៥៧ស | + ៣៦ស | + ៦៨ស |
| ៤៩ស | ២៥ស | ៤ ៤ស | |

មេរៀនទី៣.–ចំនួនពី៩០ ដល់១០០ ការរៀនរាប់- រៀនអាន- រៀនសរសេរចំនួន ។

មេរៀនទី៤.–ចំនួនដល់១០០ រៀនធ្វើលេខសងមានត្រាទុក ។

មេរៀនទី៥.– ចំនួនដល់១០០

មេលេខគុណនឹង៤-គុណចំនួននឹង៤ ។

មេរៀនទី៦.–ចំនួនដល់១០០ ចែកចំនួនជា៤ ។

សូមមើលតាមរបៀបជាគំរូខាងលើនេះ ។

## វង្វាស់-វង្វាល់

ក្នុងខែនេះគ្រូបង្រៀនឲ្យសិស្សស្គាល់ប្រាក់រៀល - ប្រាក់កាក់នឹងលុយសេន ឲ្យចេះដូរនឹងចេះថែមថយលុយ ។

មេរៀនទី ១.– លុយ ១ សេននិងលុយ ៥ សេន ។

របស់សម្រាប់បង្រៀន.– លុយ ១ សេននឹងលុយ ៥ សេន ។

របៀបបង្រៀន.– ១ ការពិនិត្យ - នាំសិស្សពិនិត្យមើលលុយ ១ សេនរូបលុយ ៥ សេនទៀតអំពី ៖

ក)-.ទំហំ - កម្រាស់ - ពណ៌ - ទម្ងន់

ខ)- អំពីរូប - អក្សរនិងលេខ ។

គ)- អំពីជាតិលោហធាតុដែលគេធ្វើលុយនោះ

ឃ)- សួរលុយដែលទម្លាក់ទៅលើតុឲ្យសិស្សស្តាប់ ។

២.– ការហាត់ដូរ - ហាត់ថែមថយ ៖

– លុយ ៥ សេន ៣ ត្រូវដូរជាលុយសេនបានប៉ុន្មានសេន ។

– លុយ ១ សេន២០ត្រូវដូរបានលុយ ៥ សេនប៉ុន្មាន ។

–លុយ ៥ សេន ៥ នឹងលុយ ១ សេន ៣ ត្រូវជាប៉ុន្មានសេន ។

–ខ្ញុំយកលុយ ៥ សេន ៧ ទៅទិញរបស់ ៣២ សេន គេត្រូវថែមមកឲ្យខ្ញុំវិញប៉ុន្មានសេន ។

– បើខ្ញុំត្រូវទិញស្លាបប៉ាកា ១ ថ្លៃ ៤៣ សេនខ្ញុំត្រូវឲ្យលុយ ៥ សេនទៅគេប៉ុន្មាន ហើយគេត្រូវថែមមកឲ្យខ្ញុំវិញប៉ុន្មានសេន ។

៣– ការហាត់សរសេរនៅក្នុងសៀវភៅ

បំណោទ.— ខ្ញុំមានលុយ ៥ សេន ៣ ទឹងលុយសេន ៧ ខ្ញុំត្រូវមានលុយទាំងអស់ .... សេន ។ បងស្រីខ្ញុំឲ្យលុយ ៥ សេន ៥ ទឹងលុយ ១ សេន ៩ មកខ្ញុំទៀត គាត់ឲ្យមកខ្ញុំ .... សេន ។ ខ្ញុំត្រូវមានលុយទាំងអស់ .... សេន ។

មេរៀនទី ២.— ប្រាក់កាក់ ១០ សេន ២០ សេនទឹង ៥០ សេន

មេរៀនទី. ៣.— ប្រាក់មួយរៀល

សូមប្រាប់សិស្សថា ឥឡូវនេះគេពុំចាយប្រាក់សាច់មួយរៀលទេ ពីព្រោះវាធ្ងន់លំបាកទឹងយកទៅណាមកណា គេចាយប្រាក់ក្រដាសវិញ ងាយទឹងយកទៅណាមកណាបានច្រើនហើយស្រាលផង ។

ការបំណាំ.— គន់វិធីបង្រៀនអំពីលុយ – ប្រាក់កាក់ – ប្រាក់រៀលត្រូវចែករបៀបបង្រៀនជាបីចំពូក ៖

ចំពូកទី១ ការពិនិត្យ

ចំពូកទី២ ការហាត់ផ្លូវ - ហាត់ថែមថយ

ចំពូកទី ៣ ការហាត់គិតដោយមាត់ទទេនិងដោយសរសេរក្នុងសៀវភៅ

ហេតុនេះសូមលោកគ្រូរកលុយ-ប្រាក់កាក់ - ប្រាក់រៀលមកបង្ហាញសិស្សកុំខាន ទើបសិស្សបានឃើញជាក់ស្តែង ឯគ្រឿងការហាត់ផ្លូវហាត់ថែមថយគ្រាន់តែកាត់ក្រដាសក្រាស់រង់មានទំហំប៉ុនលុយ - ក.ក់ ប្រាក់

រៀល ហើយសរសេរលេខ ១ស ១០ស ២០ស ៥០ស ១រ ជាសំគាល់ទៅក៏បានដែរ បើគេមកឲ្យសិស្សហាត់ដូរពុំបាន ។

# បរិច្ឆណាផ្ដាំន

## នព្វន្ត

តាមរបៀបបែកវិជ្ជាបង្រៀនក្នុងខែនេះ ត្រូវបញ្ជាក់អំពីមេលេខគុណបង្រៀនសិស្សឲ្យចេះធ្វើលេខគុណនឹងលេខបែក ចំនួនទឹងលេខហារមួយគូ ហើយឲ្យចេះគិតគុណនឹងបែកចំនួនទឹង ១០ ទឹង ១០០ ។

មេរៀនទី ១ សាបង្រៀនអំពីមេលេខគុណ ជារបៀបបញ្ជាក់ឲ្យដឹងថាសិស្សចេះមេលេខគុណច្បាស់ហើយឬនៅ ។

របៀបបង្រៀន សួររកបញ្ជាក់អំពីមេលេខគុណដូចជា៖

៧×៣= ១៥:៤= ១៩×៥= ១៧×៦= ។ល។

ដូចជា៤បីដង់ត្រូវជាប៉ុន្មាន ។ ៥ បួនដង់ត្រូវជាប៉ុន្មាន ។ល។ ចោទសួរបែបនេះឲ្យបានច្រើន ពីព្រោះមិនត្រូវឲ្យសិស្សសូត្រមេលេខគ្រាន់តែចាំថា ២ មួយដង ២ ។ ២ ពីរដង ៤ ។ ៣ ពីរដង ៦ ។ល។ ដូច្នេះទេ

គឺត្រូវឲ្យសិស្សដឹងថា៖ ៤ ពីរដងត្រូវជា ៨ ។ ៧ ពីរដងត្រូវជា ១៤ ។

ដើម្បីកុំឲ្យរបៀបបង្រៀននេះដែលនាំឲ្យសិស្សធុញទ្រាន់ ។ សូមប្រែផ្លាស់ប្ដូររបៀបចោទសួរឲ្យសិស្សឆ្លើយដោយមាត់ទទេ ដោយសរសេរនៅលើក្ដារខៀន ឬដោយចោទសួរជាចំណោទល្បងសិស្សឆ្លើយមាត់ទទេ ឬសរសេរនៅលើក្ដារខៀនបាន ។

ការហាត់សរសេរនៅក្នុងសៀវភៅ

១ ចូរគិតចំនួនខាងក្រោមនេះ

៤' × ៥ = ។ ៧' × ៩ = ។ ៨' × ៦ = ។ ៥' × ៧ = ។

ក្នុង ៤២' មាន ៦' ប៉ុន្មានដង ។ ក្នុង ៦៣' មាន ៧' ប៉ុន្មានដង ។
ក្នុង ៤៥' មាន ៩' ប៉ុន្មានដង ។ ក្នុង ៥៤' មាន ៩' ប៉ុន្មានដង ។

២- ចំណោទ- ខ្ញុំមានប្រាក់ ៣៧' ខ្ញុំទិញសៀវភៅ ៥ ថ្លៃ ៣' ក្នុងសៀវភៅមួយ ។ ខ្ញុំចាយទិញសៀវភៅអស់ប្រាក់....រៀល ហើយខ្ញុំនៅសល់ប្រាក់....រៀលទៀត ។

## មេរៀនទី ២ រៀនគុណចំនួននឹងលេខមួយតួ

### របៀបបង្រៀន.-

១- ការហាត់គិតមាត់ទទេ

ដោយសួរសិស្សអំពីមេលេខគុណ.

២ - ពន្យល់របៀបធ្វើលេខគុណ.

គ្រូដោយចំណោទមួយថា: អង្ករ ១ ហាបថ្លៃ ១៤៧៛ តើអង្ករ ៥ ហាប ត្រូវជាថ្លៃប៉ុន្មាន ។ ត្រូវធ្វើលេខគុណ ១៤៧៛ × ៥ = នេះនៅលើក្ដារខៀនឲ្យសិស្សមើលហើយពន្យល់របៀបធ្វើលេខគុណនេះ ។

៣ – ការហាត់បញ្ជាក់នៅលើក្ដារខៀន :

៤៣៛ × ៩ = ។ ៧៣៛ × ៧ = ។ ១៤៧៛ × ៤ = ។

៤ – ការហាត់បញ្ជាក់នៅលើក្ដារឥន :

៥៧៛ × ៣ = ។ ៦៩៛ × ៥ = ។ ៤១៧៛ × ២ = ។

៥ ការហាត់សរសេរនៅក្នុងសៀវភៅ :

ក) ចូរធ្វើលេខខាងក្រោមនេះ

| | | | |
|---|---|---|---|
| ២៥៛ | ៧៩៛ | ១៤៧៛ | ១២៥៛ |
| × ៧ | × ៥ | × ៣ | × ៦ |

ខ ចំណោទ – ឪពុកខ្ញុំគាត់មានប្រាក់ ៧៩៣ រៀល គាត់ចាយទិញស្រូវ ៧ ហាបថ្លៃ ៥៧៛ ក្នុងមួយហាប ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ។

មេរៀនទី ៣. – រៀនចែកចំនួននឹងលេខមួយតួ ។

របៀបបង្រៀន.- ធ្វើតាមរបៀបបង្រៀន ធ្វើលេខគុណវាង លើនេះ ។

ការហាត់សរសេរនៅក្នុងសៀវភៅ-

១- ចូរធ្វើលេខខាងក្រោមនេះ

៤៧៦ | ៤      ១៧៥ | ៥      ៣៥០ | ៧

២- ចំណោទ.- ឪពុកខ្ញុំគាត់ទិញស្រូវ ៦ ហាបថ្លៃ ៤៥០រ, ។ តើស្រូវ ១ ហាបថ្លៃប៉ុន្មាន ។ បើគេទិញស្រូវនោះ ៩ ហាបត្រូវជាប៉ុន្មាន ។

## រង្វាស់រង្វាល់

ក្នុងខែនេះត្រូវបង្រៀន អំពី លុយ - កាក់ - ប្រាក់ដែលមានចាយនៅក្នុងប្រទេសឥណ្ឌូចិន ។

របៀបបង្រៀនមានរៀបចំទុកជាគំរូនៅថ្នាក់កុមារដ្ឋានស្រាប់ហើយ សូមលោកគ្រូករបស់អស់នោះបកបង្ហាញសិស្ស ឲ្យវាពិនិត្យមើលឃើញជាក់ស្តែង- ហើយនាំហាត់ដូរហាត់ថែមថយឲ្យស្ទាត់ផង ព្រោះការទាំងនេះមានប្រយោជន៍សំខាន់បំផុត ក្នុងការចាយវាយប្រាក់និងការសំគាល់ប្រាក់ក្លែងក្លាយ ។

សូមចែកវិជ្ជានោះ បង្រៀនតាមពេលឲ្យសំល្មមផង៍សូមមើលតាមរបៀបតែងក្នុងទស្សនាវដ្ដី ឆ្នាំទី ១ លេខ ៦ សំរាប់ថ្នាក់ បរិវិច្ចណដ្ឋាន មានសព្វគ្រប់ស្រាប់ហើយ ។

---

# ទាធិកដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី ១.– មេរៀនទី ១– ខ្យល់អាកាស – ខ្យល់

ប្រដាប់បង្រៀន-ដប, ទឹក, ទៀន, កែវ, ។

ការពិសោធន៍.– ជ្រមុជដបទៅក្នុងទឹកឲ្យសិស្សឃើញពពុះស្ទុះចេញមកពពុះនេះគឺខ្យល់ដែលនៅក្នុងដប ។

អុជទៀនកណ្ដាលវាលឲ្យឆេះមួយសន្ទុះ រួចយកកែវមកគ្របទៀនរលត់គឺមកពីឥតខ្យល់អាកាស ។

សុំបាត់ថែងបង្រៀនតាមមេរៀន ក្នុងសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បរិវេចនដ្ឋានទំព័រពី ៩៦.៩៧ ។

មេរៀនទី ២.— ព្រះធរណី

ប្រដាប់បង្រៀន.— កូនគោល·ផ្លែក្រូចពោធិសាត់

មេរៀនសង្ខេប.— ដីមានរាងមូលដូចផ្លែក្រូចពោធិសាត់មានមនុស្ស នៅពាសពេញទាំងអស់ លើកលែងតែនៅផ្ចិតជើងខាងជើងនិងខាងត្បូង ។ ព្រះធរណីអណ្ដែតនៅក្នុងអាកាស ហើយវិលជុំវិញខ្លួនឯងនិងជុំវិញព្រះអាទិត្យ ។ ចំណែកណាត្រូវព្រះអាទិត្យគឺជាពេលថ្ងៃ ចំណែកណាដែលមិនត្រូវគឺពេលយប់ ។ ព្រះធរណីវិលខ្លួនឯងមួយយប់បានមួយជុំក្នុង ១ យប់មាន ២៤ ម៉ោង ។

អាទិត្យទី ២.— មេរៀនទី ១ ទឹក

សុំមើលសៀវភៅវត្ថុសាធ្យាយន៍ សំរាប់បរិវ្ឋណាដ្ឋាន ទំព័រទី ៩៧. ៩៨. ៩៩ ។

មេរៀនទី ២.— ចំហាយទឹក

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ៩៩ ទឹង ១០០ ។

អាទិត្យទី ៣.— មេរៀនទី ១— ពពកនឹងអ័ព្ទ

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ១០១ ទឹង ១០២ ។

មេរៀនទី ២.— ភ្លៀង

សុំមើលសៀវភៅដែលគ្រងទំព័រទី ១០៣ ។

អាទិត្យទី ៤· រៀនសាដើម

សុំគ្រូគេប្រដាប់ឧណ្ហមាត្រ (thermomètre) និងប្រដាប់ស្ទង់បរិយាកាស (Barometre) យកមកបង្ហាញ ហើយពន្យល់សិស្សឲ្យចេះមើលរបៀបកំណត់គំនូសតាមពេលវេលាផង ។

## វិធីបង្ការោគ

### ជម្ងឺអាសន្នរោគ

អាសន្នរោគជាជម្ងឺឆ្លងអាចរាតត្បាតមនុស្សទាំងភូមិ ៗ ឲ្យស្លាប់បាន។ ជម្ងឺនេះមានជានិច្ចជាកាលនៅប្រទេសក្លិង្គ ហើយបានបំផ្លាញជីវិតមនុស្សជាច្រើន, នៅប្រទេសចិននិងឥណ្ឌូចិន ។ កាលពីឆ្នាំ ១៩២៦ - ២៧ ជម្ងឺនេះធ្វើឲ្យវិនាសជីវិតមនុស្សនៅឥណ្ឌូចិនអស់ ១២. ០០០ នាក់ ។

១ លក្ខណៈ: រាករូសខ្លាំង (២០ ផ្ងាយដងក្នុង ១ ថ្ងៃ) ។ លាមកសុទ្ធតែទឹកហើយមានកំទេចរឹងសដូចគ្រាប់អង្ករ ទឹកមូត្រថយ ស្បែកត្រ-ជាក់ អ្នកជម្ងឺឈឺចាប់ក្នុងខ្លួនតិចណាស់ ប៉ុន្តែចេះតែស្រេកទឹក ហើយក្អួតជាញយ ៗ អ្នកជម្ងឺធាប់ហេវណាស់ហើយស្លាប់ក្នុងរវាង ២-៣ ថ្ងៃឬ ៤-៥ ម៉ោងក៏មាន ។

២ - ហេតុ ជម្ងឺនេះបណ្ដាលពី "អតិសុខុមប្រាណកើតនៅក្នុងពោះ-វៀន រាងដូចកណ្ដក់សញ្ញា ។ អតិសុខុមប្រាណនេះឆ្លងពីមនុស្សមួយទៅមួយដោយទឹក, បន្លែឆៅ, លាមក, សត្វល្អិតហើយគ្រឿងដែលអ្នកជម្ងឺប្រើប្រាស់ ។

៣ - កិច្ចការពារ.- ?

ក) - ត្រូវដាំទឹក, ចំអិនបន្លែហើយគ្របចំណីអាហារកុំឲ្យរុយទំ ។

ខ) ត្រូវកាន់តាមវិធីបង្ការរោគឲ្យណាស់ ៖ ចៀសវាងកុំឲ្យធ្វើអ្វីឲ្យខ្សោយកម្លាំង ។ ត្រូវលាងដៃឲ្យស្អាតមុនពេលបាយ

គ) ត្រូវឲ្យពេទ្យចាក់ថ្នាំដែលជាកិច្ចការពារជម្ងឺនេះកុំឲ្យរាតត្បាតបាន

៤ - កិច្ចត្រូវធ្វើ ចំពោះមនុស្សកើតអាសន្នរោគ.-

ក)- ត្រូវដាក់មនុស្សជម្ងឺនឹងពួកគ្រួសារនៅដោយឡែក ទុកឲ្យតែមនុស្សម្នាក់ចេញចូលមើលការខុសត្រូវ ។

ខ)- ឲ្យមនុស្សជម្ងឺបន្ទោបង់លាមកនឹងទឹកមូត្រក្នុងកន្ទោរដែលមានលាយទឹក "ក្រេស៊ីល" រួចយកទៅចាក់កប់ក្នុងរណ្ដៅជំរៅ ១ម ដោយមាន-ចាក់កំបោរពីលើផង ។

គ)- កប់ខ្មោចស្លាប់ដោយជម្ងឺនេះក្នុងរណ្ដៅជំរៅ ២ម ដីកឲ្យឆ្ងាយពីផ្លូវទឹកទាំងឡាយ ហើយចាក់កំបោរពីលើ ។

ឃ).– បាចទឹកកំបោរពោសពេញផ្ទះ – គ្រឿងប្រដាប់ដែលមនុស្ស ដើម្បីបានប្រើប្រាស់ទាំងប៉ុន្មាន គេងស្ងោរ ឬបាចទឹក "គ្រេស៊ីល" ។

# មជ្ឈិមដ្ឋានទី ១

## វិត្តស្វាធ្យាយន៍

### អាទិត្យទី ១.– មេរៀនទី ១ - ប្រយោជន៍នៃព្រៃឈើ

គោលសេចក្ដី.–

១– ខាងចំណីអាហារ៖ ផ្លែ, ស្លឹក, មើម............

២– ខាងគ្រឿងប្រើប្រាស់៖ ឧសដុត, គ្រឿងតុបតាំង, ឬស្សី, វល្លិ៍ ផ្ដៅ, ជ័រ .........

៣- មានប្រយោជន៍លើអាកាសធាតុ៖ ជារបាំងទប់ខ្យល់និងទាក់ទឹកភ្លៀង ធ្លាក់ឲ្យទៀងទាត់ ។

៤– សំរួលទឹកជំនន់៖ ទឹកភ្លៀងហូរកាត់ព្រៃពុំសូវលឿនគំហុកដោយមាន ដីនិងឬសឈើស្រូបទប់ ។

# មេរៀនទី ២.- ការអន្តរាយបណ្តាលពីការធ្វើព្រៃឲ្យវិនាស ។

គោលសេចក្តី.-

១- ហេតុដែលនាំឲ្យព្រៃវិនាស ៖

ក- កាប់ឈើខ្ជះខ្ជាយហួសប្រមាណ (មានរំលំដើមយកផ្លែជាដើម)

ខ- ដុតស្រែចំការមិនប្រយ័ត្នឲ្យរាលឆេះព្រៃជិតខាង ។

២- ការអន្តរាយបណ្តាលពីការធ្វើព្រៃឲ្យវិនាស ។

ក- នាំឲ្យស្រុកក្រខ្សត់ ។

ខ- នាំឲ្យប្រដាប់ប្រើប្រាស់ឡើងដំឡៃ ។

គ- នាំឲ្យភ្លៀងគ្មានកំណត់ ~~ហើយ~~ ជន់លិចលង់ស្រុកភូមិអស់ដូចនៅប្រទេសតុងកឹង ។

# អាទិត្យទី ២.- ការធ្វើកៅស៊ូ

សេចក្តីសង្ខេប.- កៅស៊ូមានកំណើតនៅប្រទេសអាមេរិកខាងត្បូង មានដ័រស ដើមវាដុះបានល្អនៅប្រទេសក្តៅ ៗ គេយកដ័រកៅស៊ូបានកាលដាំបាន ៦ ឆ្នាំ ហើយគេយកដ័រនោះធ្វើជាបន្ទះនៅក្នុងចំការកៅស៊ូតែម្តង ។ បន្ទះកៅស៊ូនេះគេសំរាតចំអិនជាថ្មីទៀតក្នុងរោងចក្រសព្វហាកម្មធំ ១ ៗ

**ប្រយោជន៍កៅស៊ូ.–** កៅស៊ូលាយនឹងជាតិមនោសិលា (ម្នាង-សិលា) នឹងច្បងឬស្ពាន់ធ័រ ប្រើការបានច្រើនយ៉ាងណាស់ ៖ បំពង់, ខ្សែ, សំពត់, កៅស៊ូកង់ ។ល។ បើគេចង់ឲ្យរឹងគេថែមស្ពាន់ធ័រឲ្យច្រើន។

**ការវៃអម្បោះនឹងការដំបាញ.–** ខ្មែរយើងច្រើនយកកប្បាសទៅបោះនឹងផ្លោះប្រយោជន៍ឲ្យខ្ចាត់គ្រាប់ចេញ ឯផ្លោះនោះគឺជាប្រដាប់មានដុំឈើមូលពីរ វិលច្រាសគ្នានឹងប្រដាប់បង្វិលមួយ កាលណាកប្បាសចូលសង្កៀតដុំឈើនោះ សំឡីក៏របូតចេញពីគ្រាប់អស់ទៅ ។ ហើយគេយកសំឡីទៅលាលើកន្ទេលមួយ ហើយបានគេតាំងផ្ដុប ។ គេយកសំឡីទៅវៃនឹងរហាត់ធ្វើជាអម្បោះ ។ ប៉ុន្តែអ្នកត្បាញប្រើអម្បោះវៃនឹងម៉ាស៊ីន ។

ឯត្បាញសំពត់នោះគេត្បាញនឹងប្រដាប់មួយហៅថាកីត្បាញ ឯការនេះច្រើនតែស្រី ៗ ធ្វើ ឯស្រីអ្នកត្បាញអង្គុយលើក្ដារកីហើយចាប់ច្រានធ្នញឈើជាន់ឈ្នាន់ជង្ករ ហើយបានទាក់ត្រល់ទៅតាមបន្ទោះខ្សែអន្ទង ប្រយោជន៍នឹងឲ្យអម្បោះចាក់ហើយនឹងអម្បោះអន្ទង់នេះខ្វែងគ្នា បានជាសាច់សំពត់ ។

ឯកប្បាសនៅប្រទេសឥណ្ឌូចិន មិនបានចំនួនគ្រប់គ្រាន់ធ្វើសំលៀក

បំពាក់អ្នកស្រុកទេ គេទិញពីស្រុកក្រៅមកក្នុងមួយឆ្នាំ ៗ បួនពាន់ប្រាំបីរយហាប ។

នៅស្រុកតុងកឹងមានម៉ាស៊ីនរវៃកប្បាស ធ្វើអម្បោះហើយត្បាញសំពត់ផង ។

## អាទិត្យទី ៣.– មេរៀនទី ១– ឧស្សាហកម្មកើតពីឈើ

ឈើមានពីរបំពូក៖ ឈើលេខ ១ និងឈើប្រើការធម្មតា

១– ឈើលេខ១ ដូចជាបេង, នាងនួនសំរាប់ធ្វើគ្រឿងតុ - តាំងប្រណីត

២– ឈើប្រើការធម្មតាដូចជាត្រាច, ឈើទាលសំរាប់ធ្វើគ្រឿងផ្ទះនិងគ្រឿងដទៃទៀតជាច្រើន ។

៣– ឫស្សីមានប្រយោជន៍ច្រើនយ៉ាង (គ្រឿងផ្ទះ, នេសាទុបករណ៍, ខេត្តុប្បករណ៍) ។

## មេរៀនទី ២.– ការធ្វើក្រដាស

ក្រដាសកើតពីសរសៃរុក្ខជាតិផ្សេង ៗ ដូចជាកប្បាស, បំបើងឬសាច់ឈើ ៗ នៅប្រទេសឥណ្ឌូចិនគេធ្វើនឹងដើមមន ដើមឫស្សី ដើមស្បូវ បំបើងឬកំណាត់សំពត់ចាស់ ៗ ។ គេយកជាតិទាំងនេះមកបិញ្ច្រាំហើយស្ងោរជាមួយនឹងក្បុងខ្សែស ។ ក្រដាសសរសៃរមានលាយជាតិការផង ក្រដាសផ្តិតគ្មានជាតិការទេ ។

អាទិត្យទី ៤.– រៀនសាដើម

## វិធីបង្ការរោគ - រោគរបេង

គោលសេចក្ដី.– ជារោគធ្ងន់អាចចាប់គ្រប់អវយវៈក្នុងខ្លួន ៖ ឆ្អឹង, គ្រឿងប្រដាប់វិញ្ញាណ, គ្រឿងប្រដាប់រំលាយ អាហារ, ស្បែក ប៉ុន្តែ ច្រើនចាប់នៅសួត ។

១– លក្ខណៈ: រោគរបេងស៊ីសួតចាប់ពីផ្ដាសាយធម្មតា រួចបណ្ដាលជាក្អកឆ្អាក់ស្លេស្ម ៗ ខ្លួនចេះតែក្ដៅពេលអាស្រ័យអ្វីពុំបាន ៗ ក្អកកាន់តែមានស្លេស្មខាប់ឡើង ហើយញាប់ឡើងៗ ម្ដងៗវែងៗ កំហាកមានឈាម ខ្លះនឹងឈាម ៗ អ្នកជំងឺស្លាប់ដោយរីងរោះក្នុងខ្លួន ៗ

២.- ហេតុ– បណ្ដាលពីអតិសុខុមប្រាណកុក" (កុកជាឈ្មោះវេជ្ជៈបណ្ឌិតដែលរកឃើញមេរោគនេះ). មាននៅក្នុងកំហាក - កំហាកស្ងួតទៅកើតជាធូលីហុយ នាំមេរោគនេះពេញពាស អាចចូលក្នុងសួតយើងបានតាមខ្យល់ដកដង្ហើម ៗ រោគរបេងអាចឆ្លងតាមប្រដាប់រំលាយ-អាហារដែរ កាលណាយើងអាស្រ័យសាច់ពុំឆ្អិនល្អឬយើងអាស្រ័យទឹកដោះគោកើតរបេងពុំបានដាំឲ្យឆ្អិន ៗ

រោគរបេងមិនមែនជម្ងឺឆ្លងស្នូវពូជឡើយ កូនអ្នករបេងកើតឡើងគ្មានជាប់រោគរបេងមកជាមួយឡើយ ៗ កាលណាគេយកកូននេះទៅ

ចិញ្ចឹមឆ្ងាយពីមាតាបិតា ពីរ៉ះនៅស្រុកសាជដូចគេឯង ។

៣ – កិច្ចត្រូវការពារខ្លួន .-

១ – បរិភោគចំណីអាហារស្អាតហើយគ្រប់គ្រាន់ - នៅផ្ទះស្អាតត្រូវហាត់ប្រាណហាលថ្ងៃនៅកណ្ដាលខ្យល់អាកាស ។

២ – ជៀសវាងកុំឱ្យបាក់កម្លាំង - កុំឱ្យប៉ះត្រជាក់ខ្លាំង ។

៣ ត្រូវចាក់ថ្នាំតារក"

៤ ត្រូវព្យាបាលរោគផ្ដាសាយកុំបណ្ដោយ ។

៥ – ជៀសវាងកុំឱ្យខាកស្ដោះលើដី ។

៦ ធ្វើកិច្ចសម្លាប់មេរោគឬដុតចោលអស់ទាំងប្រដាប់ប្រដាអ្នកជម្ងឺ ។

---

បរិច្ឆណាដ្ឋាន

## វិត្តស្មាធ្យាយន៍

### អាទិត្យទី ១.– អំពីសត្វឆ្មា

សូមគ្រូចាប់ឆ្មាតូចមួយយកមកបង្រៀន នាំសិស្សពិនិត្យមើលឆ្មា ។

ក្បាលឆ្មាដូចម្តេច ? ឲ្យសិស្សសង្កេតមើលស្បែកឆ្មា ។ ពណ៌ដូចម្តេច? មានអ្វីជាបំប្លែកពីស្បែកសត្វឯទៀត? សត្វអ្វីទៀតដែលមានស្បែកដូចឆ្មា? នៅមាត់មានអ្វី? ឯពុកមាត់នេះប្រើការដូចម្តេច? សូមឲ្យបើកមាត់វាមើលធ្មេញឆ្មា សណ្ឋានដូចម្តេច? ធ្មេញណាធំជាងគេ? ហេតុដូចម្តេចបានជាចង្កូមនេះធំជាងធ្មេញឯទៀត? ព្រោះឆ្មាបរិភោគសាច់ចង្កូមដុះធំឡើង ដើម្បីនឹងទំពាសាច់ ធ្មេញសត្វណាដែលបរិភោគសាច់ ក៏ដូច្នេះដែរ? (ដូចជាឆ្កែ-ខ្លា-តោ) ។

ឲ្យសិស្សមើលខ្លួនឆ្មា-រោមឆ្មាសណ្ឋានយ៉ាងណា? ពាល់ទៅដូចម្តេច ឲ្យសិស្សសង្កេតមើលជើងឆ្មា ឆ្មាមានជើងប៉ុន្មាន? សត្វដែលមានជើងបួនហៅថាសត្វអ្វី? នៅចុងជើងមានអ្វី? ក្រចកឆ្មាយ៉ាងដូចម្តេច? (កោងខ្ទុបចុះក្រោមស្រួច លបចូលលូតចេញបានតាមចិត្ត) ។ ឯក្រចកនេះសម្រាប់អ្វី ។ ចាប់ក្រញាំសត្វជាអាហារ ។ ហេតុដូចម្តេចបានជាឆ្មាលាក់ក្រចកកាលណាវាដើរ? (កុំឲ្យស្រឹក) កាលណាវាបញ្ចេញក្រចក ឲ្យឆ្មាដើរ-លោត ដំណើរឆ្មាយ៉ាងដូចម្តេច? ដើរលប ៗ ដំណើរទន់ភ្លន់ ប៉ុន្តែឆ្មាខ្លាំងហើយរហ័សណាស់ កាលណាវាចាប់សត្វបរិភោគឬមួយតយុទ្ធនឹងសត្រូវ សុំឲ្យគ្រូនិយាយអំពីពុតឆ្មា ហើយតែងសេចក្តីសង្ខេបផងចុះ ។

មេរៀនទី ២ អំពីគោ

## អាទិត្យទី ២ .– អំពីមាន់

វត្ថុសម្រាប់បង្រៀន - មេមាន់ ពងមាន់ រូបក្អែក នាំសិស្សពិនិត្យមើលក្បាលមាន់ ភ្នែក ក ទងចំពុះមាន់ ចំពុះវាស្រួចសម្រាប់ចឹកអាហារ ៗ មានអ្វីដុះរុំពីខ្លួន (មានរោមតូច ១) រោមនេះប្រយោជន៍ដូចម្ដេច ៗ គ្របដណ្ដប់ខ្លួនការពារត្រជាក់ ៗ នៅសងខាងខ្លួនមានអ្វី- (មានស្លាប២) ស្លាបនេះប្រយោជន៍ដូចម្ដេច ? មាន់មានជើងប៉ុន្មាន? នៅចុងជើងមានអ្វី?

ឲ្យសិស្សស្ទាបមើលខ្លួនមាន់ហេតុដូចម្ដេចបានជាក្ដៅខ្លាំង៖ ព្រោះឈាមរត់ញាប់ណាស់ មាន់កើតកូនដូចម្ដេច? ចិញ្ចឹមកូនដូចម្ដេចលក្ខណសត្វចតុប្បាទនិងសត្វទ្វិបាទ សត្វស្លាបឲ្យសិស្សធៀបសត្វចតុប្បាទនិងទ្វិបាទខុសគ្នាយ៉ាងណាខ្លះ? ដូចក្អែកនឹងមាន់ ៗ ល ៗ

## មេរៀនទី ២ អំពីត្រី

វត្ថុសម្រាប់បង្រៀន ត្រីមានស្រកា - ពងត្រីទឹកមួយក្អាំ ៗ

នាំសិស្សពិនិត្យមើលត្រី ៗ ខ្លួនរាងដូចម្ដេច? វែងធំកណ្ដាលចុងដើមស្រួច ដើម្បីកុំឲ្យពទឹក ៗ លើខ្លួនមានដុះអ្វី? ព្រុយដែលដុះនៅលើខ្នងចុះក្រោមពោះគេហៅព្រុយអ្វី? ត្រីមានស្រកាប៉ុន្មាន? នៅត្រង់ណានាំសិស្សមើលត្រីហែល - ព្រុយខ្នងហើយនិងព្រុយពោះ ប្រយោជន៍ដូចម្ដេច ? ( កកាយទឹកឲ្យលឿនទៅមុខ ) ព្រុយកន្ទុយប្រយោជន៍ដូចម្ដេច

(ប្រើជាបន្ទុកប្រយោជន៍បត់ចុះបត់ឡើង) ។ ព្រួយខ្លួនហើយនឹងព្រួយឯទៀត (សំរាប់ទប់ទល់ត្រីឲ្យនៅនឹងបានក្នុងទឹក) ។ ហេតុដូចម្ដេចបានជាស្រកីពណ៌ក្រហម ? (ព្រោះមានឈាម) ។ ត្រីដកដង្ហើមតាមស្រកីនេះឯង ត្រីទុកនៅលើគោករស់នៅបានឬទេ? យកពងត្រីឲ្យសិស្សមើល ត្រីកើតកូនដូចម្ដេច? ឲ្យសិស្សរាប់ឈ្មោះត្រីណាដែលស្គាល់ ។

អាទិត្យទី ៣ .- អំពីបង្កួយ - កង្កែប

អាទិត្យទី ៤ .- អំពីមេអំបៅ - ឃ្មុំនិងដង្កូវ ។

---

បរិច្ឆេទណដ្ឋាន

វិធីបង្ការរោគ

អាទិត្យទី ១ .- កិច្ចដែលត្រូវប្រព្រឹត្ត នៅវេលាដែលមានជម្ងឺធ្ងន់ រំលឹកសិស្សថាក្នុងគ្រាឥឡូវនេះមានជម្ងឺធ្ងន់ ដូចជាជម្ងឺអាសន្នរោគ (ជម្ងឺនេះធ្ងន់រហ័សណាស់ធ្វើឲ្យអ្នកស្រុកវិនាស ហេតុនេះត្រូវឲ្យប្រយត្នមាំមួន ឲ្យសិស្សរៀបរាប់អំពីជម្ងឺដែលឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត អ្វីដែលនាំជម្ងឺពីម្នាក់ទៅម្នាក់ទៀត ។

កាលណាមានជម្ងឺឆ្លងនៅក្នុងផ្ទះ ត្រូវឲ្យមានសេចក្ដីប្រយ័ត្នដូចមានអាង ក្រោមនេះ បំបែកអ្នកជម្ងឺឲ្យនៅដោយខ្លួន អ្នកថែជម្ងឺត្រូវមានសម្លៀកបំពាក់មួយប្រដាប់ផ្សេងមួយសម្រាប់ ចូលទៅក្នុងបន្ទប់ជម្ងឺ ត្រូវលាងដៃនឹងទឹកសាប៊ូរួចទឹកស្រា កាលណារួចការហើយ ៗ

អាទិត្យទី ២ - កិច្ចដែលត្រូវប្រព្រឹត្តនៅវេលា ដែលមានជម្ងឺឆ្លង ( តមក )

ការរំងាប់នឹងផៀសមេរោគវេលាដែលអ្នកមានជម្ងឺមិនទាន់ជា ត្រូវឲ្យសំអាតទីលំនៅតុទូតាំង មិនត្រូវឲ្យមានសំរាមស្អុយរលួយនៅជិតផ្ទះ សម្បែងកុំប្រើប្រាស់របស់អ្នកជម្ងឺ ដល់អ្នកជម្ងឺជាហើយ ទីកន្លែងអ្នកជម្ងឺត្រូវសំអាតរំងាប់មេរោគនឹងទឹកក្រេស៊ីល បើកទ្វារបង្អួចឲ្យស្រឡះ ឲ្យពន្លឺនឹងអាកាសចូលឲ្យបានច្រើន ៗ សំលៀកបំពាក់អ្នកនោះ ត្រូវយកទៅលាងស្ងោរចេញ ប្រដាប់ប្រដាដែលអ្នកចាប់កាន់ប៉ះពាល់ក៏ត្រូវធ្វើដូចនេះដែរ ៗ

អាទិត្យទី ៣.– កិច្ចដែលត្រូវប្រព្រឹត្ត វេលាដែលមានជម្ងឺឆ្លង(ត)

( ការប្រយ័ត្នខាងចំណីអាហារ សុំឲ្យគ្រូហាមប្រាមសិស្សកុំឲ្យបរិភោគផ្លែឈើខ្ចីដូចជាស្វាយខ្ចីជាដើម បន្លែស្រស់ឬផ្លែឈើណាដែលស្អុយរលួយ ទោះបន្តិចបន្តួចក៏ដោយ ៗ

នៅផ្ទះសម្បែងចំណីអាហារត្រូវគ្របឲ្យជិតកុំឲ្យរុយពាម អាហារទៀត ត្រូវឲ្យធ្វើថ្មីៗ ហើយចំអិនប្រាកដ គឺទុកឲ្យយូរលើភ្លើងសមបរិភោគ ។

ក្រៅផ្ទះ ដូចជាទឹកនេះក៏ដែរ បើប្រើទឹកទន្លេឬទឹកអណ្តូងត្រូវយកដាំឲ្យពុះចំនួន ២០ មីនុតការប្រើទឹកតែ ក៏ជាកិច្ចមួយ យ៉ាងសំខាន់ដែរ ក៏ប៉ុន្តែត្រូវឲ្យទឹកពុះយូរ ហើយមិនត្រូវចាក់ទឹកត្រជាក់លាយវេលារៀបនឹងផឹក ។

ការប្រយ័ត្នជាធំ បើកាលណាជម្ងឺឆ្លងក្នុងភូមិក្នុងស្រុកហើយ ត្រូវតែចូលទៅឲ្យគ្រូពេទ្យចាក់ថ្នាំការពារខ្លួនជាប ។

សុំគ្រូតែងសេចក្តីសង្ខេបផងចុះ ។

អាទិត្យទី ៤. សាបង្រៀនជាថ្មីឡើងវិញ ។

---

## កុមារដ្ឋាន ឆ

## វត្ថុស្វាធ្យាយ

### អាទិត្យទី ១ – អំពីខ្យល់អាកាស

វត្ថុសំរាប់បង្រៀន· ផ្តិល១ កូនចបតូច ទឹក១កែវ នាំសិស្សសង្កេតបង្ហាត់ឲ្យដឹងថាមានខ្យល់នៅគ្រប់ទីដំបន់ ។ ឲ្យសិស្សទាំងអស់គ្នាយក

សៀវភៅបក់មុខខ្លួនឯង ល្ហើយឬទេ ? ។ ពីព្រោះអ្វី ? ដោយមានខ្យល់មកប៉ះនឹងមុខ ។ ហេតុដូចម្តេចបានជាស្លឹកមែកឈើកំរើក ? មកអំពីមានខ្យល់បក់ផាត់ ។ យើងមើលខ្យល់ឃើញឬទេ ? យើងមើលពុំឃើញទេ ។ តើមានក្លិនឲ្យយើងសំគាល់បានឬទេ ? ខ្យល់ឥតក្លិនទេ ។ ដូចម្តេចបានជាយើងដឹងថាមានខ្យល់ ? ព្រោះយើងសំគាល់ដោយខ្យល់មាននៅកន្លែងណាខ្លះ ? មានគ្រប់តំបន់នៅជុំវិញខ្លួនយើង ។ សូម្បីតែបន្ទោះតូចមួយក៏មានខ្យល់ដែរ ។ សូមឲ្យគ្រូយកកូនដបទៅជ្រមុជក្នុងទឹក ឲ្យសិស្សពិនិត្យមើលពពុះខ្យល់ដែលផាត់ឡើង ។

ខ្យល់មានផលប្រយោជន៍ដូចម្តេចខ្លះ ? មនុស្ស - សត្វ - ដើមឈើ នៅក្នុងទឹកលើគោករស់បានតែដោយសារខ្យល់ ។ បើសិនណាជាគេយកកូនសត្វអ្វីមួយទៅដាក់ក្នុងកែវហើយគ្របឲ្យជិត កូនសត្វនោះនឹងស្លាប់ដោយគ្មានខ្យល់ដកដង្ហើម មនុស្សយើងដែលស្លាប់នឹងលង់ទឹកនោះក៏មានសណ្ឋានដូចគ្នាដែរ ។

## មេរៀនទី ២ -. អំពីខ្យល់បក់

## អាទិត្យ ទី ២ - អំពីទឹក អំពីភ្លៀង

## អាទិត្យ ទី ៣.- អំពីព្រែក អំពីសមុទ្រ

# អាទិត្យ ទី ៤.- រៀនសាអំពីដើមឡើងវិញ

សូមគ្រូតែងរបៀបបង្រៀនដូចរបៀបអធិប្បាយខាងលើនេះ ។

## កុមារដ្ឋាន

### វិធីបង្ការរោគ

មេរៀនទី ១_ អំពីការសំអាតនៅទីធ្លាសាលារៀនទាំងជាយ ៗ ។

សូមគ្រូប្រាប់សិស្សថានៅទីធ្លាសាលារៀនត្រូវឲ្យស្អាតជានិច្ចមិនត្រូវយកក្រដាសឬកាគអំពៅឬវត្ថុអ្វីៗ ដែលនាំឲ្យមិនស្អាតទៅបាចសាចនៅទីនោះទេ ពីព្រោះទីនេះហើយគឺជាទីលំអមួយដែរ អ្នកទាំងឡាយគេដើរទៅមកគេសំគាល់ឃើញថាបើទីនេះស្អាត កន្លែងឯទៀតក៏ស្អាតដូចគ្នាដែរ ខាងក្រៅក៏ដូចខាងក្នុងបន្ទប់រៀនដែរ ។

កន្លែងណាៗក្តី ដែលគេមើលទៅឃើញល្អគឺដោយមានសួនច្បារ ដោយមានមន្ទីររៀបរយ ឯទីធ្លាសាលាអ្វីបើគ្មានសួនច្បារគ្មានមន្ទីររៀបរយ បើជាស្អាតជានិច្ចក៏ល្អដូចទីដែលមានសួនច្បារមានផ្ទះត្រឹមត្រូវនេះដែរ ។

## មេរៀនទី ២–. អំពីការសំអាតបន្ទប់

សូមគ្រូប្រាប់សិស្សថា បើនឹងត្រូវការទៅបន្ទប់ បត់ជើងធំ ត្រូវឲ្យបំប្រហោង មិនត្រូវទៅខុសពីកន្លែងដែលគេសម្រាប់ឲ្យធ្វើនោះទេ ឬជតបន្ទប់ ឬខាងៗជាយ ឯបត់ជើងតូចក៏ដូច្នេះដែរ ត្រូវឲ្យត្រង់កន្លែងដែលគេបំរុងទឹងឲ្យបត់ជើងនោះ ទោះបីបើជារសួកទន់យ៉ាងណាក៏ដោយ មិនត្រូវទៅធ្វើតែពាស ដូចគេឃើញតែគ្រប់សាលា ត្រង់កន្លែងដែលដោះទុក្ខសត្វមិនស្អាតសោះ បើកាលណាមិនស្អាតដូច្នេះទេ ទឹងបណ្ដាលឲ្យធុំក្លិនមកដល់ទីកន្លែងដែលរៀនសូត្រ នាំឲ្យធ្វើការមិនកើត ទៅជាខ្យល់ចាប់ឬវិលមុខដោយសេចក្ដីស្អុយគ្រោកនោះម្យ៉ាងទៀតនឹងនាំបណ្ដាលឲ្យមានជម្ងឺផង ។

---

## លោកនីតិ

(សម្រាប់គ្រប់ថ្នាក់)

### ៣– សាលាដំបូង

លាសាដំបូងតាំងនៅគ្រប់ទីរួមខេត្តទាំងអស់នៃកម្ពុជរដ្ឋ ។ សាលាដំបូងខេត្តកណ្ដាលគឺសាលាលុឃុន នៅក្រុងភ្នំពេញ ខាងមុខព្រះបរម-ពជវាំង ។

នៅសាលាដំបូងនីមួយៗ មានចៅហ្វាយសាលា មានព្រះរាជអាជ្ញា សុភាចារបុរសក្រឡាបញ្ជីនិងសមុហបញ្ជី ។ សាលាដំបូងសម្រាប់ជំនុំជំរះកាត់សេចក្ដីរឿងអាជ្ញាគតិបានត្រឹមតែបទមជ្ឈិមទេ គឺធ្វើទោសដាក់គុកពី ៦ ថ្ងៃទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់តាមកំណត់ច្បាប់សម្រេចទុកមក ។ បើនៅខេត្រណាគ្មានសាលាលហុនោះសាលាដំបូងក៏ត្រូវជំនុំជំរះបទលហុដែរ ។

## ៤– សាលាក្រុមចោទ

សាលាក្រុមចោទ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិនិត្យមើលពាក្យចោទផ្សេងៗ ដែលគូក្ដីមិនសុខចិត្តនឹងការជំនុំជំរះនៅសាលាដំបូងនានា ។ លុះបានពិចារណាមើលរឿងទាំងនោះឃើញថាត្រឹមត្រូវហើយ ឬមួយនៅចន្លោះកិច្ចម្យ៉ាងៗ ពុំទាន់បានពោលសេចក្ដីបរិបូណ៌ ក៏ធ្វើភាគមានតាមហេតុពិនិត្យនោះជូនទៅសាលាឧទ្ធរណ៍ជំនុំជំរះ ។

សាលាក្រុមចោទនេះជាសាលាជំនួយនៃសាលាឧទ្ធរណ៍ ។

## ៥– សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានតែមួយទេ តាំងនៅក្រុងភ្នំពេញសម្រាប់ពិភាក្សាកាត់សេចក្ដីសាជាថ្មី ដែលគូក្ដីមិនសុខចិត្តនឹងសាលាលហុ សាលាដំបូងដែលជំនុំជំរះកាត់សេចក្ដីបើកផ្លូវឧទ្ធរណ៍ អំពីបទលហុក្ដី មជ្ឈិមក្ដី ។

## ៦_ សាលាឧក្រិដ្ឋ

សាលាឧក្រិដ្ឋសម្រាប់ជំនុំជំរះទោសធ្ងន់ដែលចូលជាបទឧក្រិដ្ឋ តាំងពីទោស ៦ ឆ្នាំទៅដល់ទោសអស់ជីវិតឬត្រូវពិឃាតជីវិតបង់ ។

បើមិនសុខចិត្តនឹងសាលក្រមសាលាឧក្រិដ្ឋទេ ត្រូវប្ដឹងទៅសាលាវិនិច្ឆ័យជាសម្រេច ។

## ៧_ សាលាវិនិច្ឆ័យ

សាលាវិនិច្ឆ័យក៏មានតែមួយ ដូចជាសាលាឧទ្ធរណ៍នឹងឧក្រិដ្ឋដែរ តាំងនៅក្រុងភ្នំពេញ ជាសាលាធំបំផុតសម្រាប់ពិនិត្យរឿងហេតុនឹងជំនុំជំរះសាឡើងវិញ ក្ដីណាគូវិវាទប្ដឹងសាទុក្ខមិនសុខចិត្តនឹងសាលក្រមសាលាលហុ, សាលាដំបូង, សាលាឧក្រិដ្ឋ, សាលាឧទ្ធរណ៍, បើពិភាក្សាទៅឃើញថា កាត់ខុសនឹងច្បាប់ក៏ជំនុំជំរះសាជាថ្មីឡើងវិញ ឲ្យបានត្រឹមត្រូវ បើឃើញថាជំនុំជំរះបានសុចរិតត្រឹមត្រូវហើយនោះត្រូវបដិសេធពាក្យបណ្ដឹងសាទុកចោលចេញ ។

សាលាជំនុំជំរះក្ដីក្នុងកម្ពុជរដ្ឋ ផុតអស់ត្រឹមសាលាវិនិច្ឆ័យនេះហើយ ។

# មេសូត្រត់មាត់

(សំរាប់គ្រប់ថ្នាក់)

## ១– ក្រុមញាតិចៅកេត

ក្នុងក្រុមគ្រួសារ ចៅកេតកុមារ មានឪពុកម្តាយ
បងប្រុសពីរនាក់ រួមរក្សសប្បាយ ប្អូនស្រីឆោមឆាយ
ចៅកេតម្នាក់ផង ។ ម្តាយវាក្មេងជាង ឪពុករវាង
បីឆ្នាំគន្លង ប្អូនស្រីក្មេងជាង វាពីរឆ្នាំផង
ចៅកេតមានបង ប្អូនវាច្រើនទៀត ។ កូននៃមីងវា
បងប្អូនត្រូវជា ជីដូនមួយឥតឃ្លាត, បងជីដូនមួយ
ជាបុរសជាតិ ទើបនឹងខ្លឃ្លាត ដណ្តឹងភរិយា ។
ជីតាខាងឪ ចៅកេតស្លាប់ទៅ យូរឆ្នាំហើយណា
ជីដូនមេម៉ាយ គាត់ចាស់ជរា ជីដូនជីតា
ខាងម្តាយនៅរស់ ។ ជួនគាត់ទៅនៅ ជាមួយនឹងចៅ
មានភរិយានោះ ជួនកូនប្រសា ស្រីចិត្តសប្បុរស
អញ្ជើញទាំងអស់ ទៅនៅជាមួយ ។

ពាក្យពន្យល់.– រួមរក្ស = (ម. ថ. ពាក់) រួមគ្នារក្សា, ជួយរក្សាគ្នា ។
បុរសជាតិ = ប្រុស ។

## ២- អំពីនេសាទត្រី

ថ្ងៃឈប់សំរាក ខ្ញុំយាត្រាចាក គេហដ្ឋានទៅ
ជូនបងប្រុសខ្ញុំ ដើរចំសំដៅ តម្រង់លំនៅ
នេសាទមច្ឆា ៗ លុះបានទៅដល់ អង្គុយក្បែរគល់
នៃដើមរុក្ខា នៅមាត់ត្រពាំង ត្រជាក់អស្ចារ្យ
បងខ្ញុំមីមា ដោតនុយសន្ទូច ៗ ដោតហើយបោះទៅ
ខ្សែរទេរនៅ កំសួលមួយតូច កំសួលកំរើក
ចិត្តខ្ញុំគិតផ្អួប មានត្រីធំ - តូច មកស៊ីនុយហើយ ៗ
លុះយូរបន្តិច កំសួលនោះលិច មើលពុំឃើញឡើយ
បងខ្ញុំវ៉ាត់ភ្លាម ជាប់ត្រីមួយហើយ ខ្ញុំចាប់មាត់ផ្ទើយ
ដោះដាក់កញ្ច្រែង ៗ ស្ទួចបានត្រីក្រាញ់ ត្រីរ៉ស់ត្រីលេញ
កញ្ចុះអណ្តែង ជូនស្ទួចមួយពេល បានគាបកញ្ច្រែង
យកមកចាត់ចែង ស្ទីរបីពេល ៗ

ពាក្យពន្យល់.- យាត្រា (ម. ថ. យាត - ត្រា = ការដើរ ៗ គេហដ្ឋាន = ផ្ទះ ៗ មច្ឆា = (ម. ថ. ម៉ាច់ឆា) ត្រី ៗ រុក្ខា = ដើមឈើ ៗ

## ៣- វាយោធាតុ (ធាតុខ្យល់)

មើលស្លឹកនៃរុក្ខា    ធ្វើសញ្ញាគួរតែដឹង
កំរើកនៅមិននឹង    គេអ្នកដឹងអ៊ូនាំវា ។
តាមពិតគិតជាខ្យល់    បក់ប្របល់សព្វសាខា
ខ្យល់នោះតាមពិតជា    អាកាសរំជួយសុស ។
បើខ្យល់តិច ៗ ទេ    កំរើករសាខានោះ
គួរតែយើងឲ្យឈ្មោះ    ខ្យល់តូចឬខ្យល់រំភើយ
បក់ពីសមុទ្រហៅ    ខ្យល់រដូវនាំរហើយ
វាតាតុំទៀងឡើយ    ជួនបក់ពីទិសឦសាណ ។
បើបក់ពីទិសនេះ    ស្រួលអ៊ីម៉េះសុខក្សេមក្សាន្ត
បើខ្យល់បក់ក្លាហាន    អប្រមាណហៅខ្យល់ព្យុះ
ឬហៅព្យុះសង្ឃរា    ទុក្ខវេទនាកើតដល់មនុស្ស
គឺរំលើងរំលុះ    រុក្ខជាតិគេហដ្ឋាន ។
ហេមន្តរដូវ    ខ្យល់បក់ត្រូវត្រជាក់មាន
រងាសព្វសុសប្រាណ    តែងបក់ពីទិសឧត្តរ ។

ពាក្យពន្យល់.— សញ្ញា = សេចក្ដីសំគាល់ ។ សាខា = មែកឈើ ។ វាតា = ខ្យល់, អាកាស ។ អប្រមាណ = (ម. ថ.

អ័ប-(ប្រ.-មាន) ដែលឥតប្រមាណ, ប្រមាណពុំបាន ។ ហេមន្តរដូវ= រដូវមានទឹកសន្សើម,រដូវរងា ។ រុក្ខជាតិ= ដើមឈើ ។ ព្យុះសង្ឃរា= ព្យុះយ៉ាងសម្បើម ។

## ៤- ចម្លាក់

ជាងឆ្លាក់ឈ្លាសពិចិត្ត . ប្រសើរអគ្គខាងរចនា
ឆ្លាក់ដែកឬសិលា ឬឈើក្តារទន្តាសត្វ ។
ឲ្យក្លាយជារូបសត្វ យក្សគន្ធព្វល្អពេកក្តាត់
ក្រីជាបក្សាសត្វ វល្លិព័ន្ធព័ន្ធស្តម្ភប្រាសាទ ។
ទោះរូបទេវតាគ្រុឌ ច្បាំងតយុទ្ធអ្នកពេជ្រឃាដ
អាចឆ្លាក់បានច្រើនទៀត ល្អហើយស្អាតសមក្រៃពេក ។
យ៉ាងក្បាច់នគរវត្ត រូបព័ន្ធព័ន្ធច្រើនអនេក
យូរហើយឥតបាក់បែក ជាងឆើតឯកបានរចនា ។
សោតឯជាងឆ្លាក់នោះ ជាប់ទម្ងុះអស់សិលា
ឬដែកនេះជាអាទិ៍ ដោយដែកជាប់មុតពិសេស ។

ពាក្យពន្យល់.—ពិចិត្ត=(ម.ប ពិ ចាក់) ឈ្លាស, ប៉ិន, ប្រសប់ ។ អគ្គ=(ម.ប អាក់)ប្រសើរ សិលា=(ម.ប ឡា)ថ្ម ។ ទន្តា=ធ្មេញ, ភ្លុក ។ គន្ធព្វ=ទេវតាពួករបាំ ។

វុល្មិ=)ម ថ រ៉ាល់)លតា ៗ ស្ដម្ភ=

ម ថ ស្ដុំ)សសារ ៗពេជ្ឈឃាត=អ្នក

ពិឃាតមនុស្សពោស ៗ អនេក=(ម ថ

អះណែក ច្រើន ៗ អាទ៌=(ម ថ អា)

ផាដើម ៗ

## ៥– គំនូរ

រូបគូរប្រសើរពិត ជាងពិចិត្រដូចសុទ្ធសាធ
ធំតូចសមរម្យស្អាត ត្រូវតាមខ្នាតផ្ទៃក្រឡា ៗ
ថ្លៃថ្នូរជាងរូបថត មានទ្រង់ផតតាមរចនា
សណ្ឋានព័ណ៌ខុសគ្នា ស្រស់សោភាគ្មានទំនាស់ ៗ
ពីសិល្បពិសេសក្រៃ ស្លឹកឈើព្រៃហាក់ដូចលាស់
រូបទេប៉ុន្តែស្រស់ ហាក់ដូចមនុស្សមានដង្ហើម ៗ
អ្នកបេះគូរល្អឯក គំនិតបែកពូកែធ្ងើម
ប្រត្យក្សគ្រូសម្បើម កិច្ចនេះផ្ដើមពីពិចារណ៍ ៗ
ពិនិត្យគិតតែគ្នេរ ត្រិះរិះវេលុះយល់ការ
ទាំងយល់កិច្ចនានា ដូចយ៉ាងពាណិជ្ជកម្ម ៗ
ប្រទេសមានអារ្យធម៌ វិចិត្រករយ៉ាងមុតមាំ
រុងរោចន៍ពូជឧត្ដម ព្រោះអប់រំវិទ្យាថ្ងៃ ៗ

ពាក្យពន្យល់.— សុទ្ធសាធ= គ្រប់ព្រម, ដូចសុទ្ធសាធ ។ ពិសិដ្ឋ= ដែលឧត្តម, ខ្ពង់ខ្ពស់ ។ ប្រត្យក្ស= (ម. ថ. ប្រត-យ័ក) ពិតប្រាកដ ។ ពាណិជ្ជកម្ម= ការលក់ដូរ, របរលក់ដូរ ។ ពិចារណ៍= (ម. ថ. ចា) ពិនិត្យពិចារណា ។ វិចិត្តករ= អ្នកពិចិត្រ ។ វិទ្យា= វិជ្ជា ។ រុងរោចន៍= (ម. ថ. រោច) ដែលរុងរឿង ។ អារ្យធម៌= (ម. ថ. អា-ធម៌) ប្រទេសមានសេចក្តីចំរើន ។ អប់រំ=ខំប្រឹងបំពេញ ។

## មេសូត្រត់មាត់

សំរាប់ កុមារដ្ឋាន-បរិវច្ឆដ្ឋាន និងអាទិកដ្ឋាន

### ១_ រំលឹកជាតិ (បទកាកគតិ)

ហៃអស់កុមារ នាំគ្នាសិក្សា កុំថាប្រុសស្រី គឺអ្នកនេះហើយ
ដែលត្រូវឃ្លាតខ្វី ការពារទឹកដី ទៅអានាគត ។
ចូរញ៉ាំងប្រាសាទ ដែលចេទាស្អាត លើផ្ទាំងសំពត់ គឺអង់ខង់
ជាតិ ត្រូវតែផ្គង់ផ្គត់ កុំឲ្យរលត់ ពីផែនទីលោក ។

ពាក្យពន្យល់: ឃ្មាតខ្មី = ខំការពារដោយអង់អាច, ដោយននះ នរនាដ ។ អនាគត = ពេលនៅខាងមុខ ឬពេលមិនទាន់មកដល់ ។ ញុំាងប្រាសាទ = លើកដំកើងប្រាសាទគឺទង់ជាតិរបស់យើង ។ ផ្គង់ផ្គត់= ទំនុកបំរុងកុំឲ្យខ្វះខាតអន្តរាយ ។ រចនា = ធ្វើឲ្យល្អប្លែកចាកភាពដើម ។ ផែនទីលោក = គំនូសដែលគេគូសភ្ជាប់នឹងគូគោល ។

---

## ២ – ដាស់តឿនជាតិ (បទពាក្យប្រាំពី)

កូនខ្មែរស្រីប្រុសត្រូវស្រុះគ្នា ខំរៀនវិជ្ជាកុំបីធ្វេស
យើងប្រឹងរើខ្លួនក្នុងជាន់នេះ កុំឲ្យប្រទេសថោកទាបទៀត ។
ស្រុកគេជិតខាងចេះដឹងច្រើន គេខំក្រើនប្រឹងឆ្លាសឆ្លៀត
តែយើងប្រហែសក្រែងធ្លាក់ស្មៀត ធ្លាក់ខ្ញុំម្តងទៀតកូនចៅ ។

ពាក្យពន្យល់ ស្រុះគ្នា = ខំរៀនសូត្រទាំងអស់គ្នា ។ កុំបីធ្វេស = កុំគិតថាមិនបាច់រៀនសោះ ឬរៀនតែបន្តិចបន្តួចក៏បានហើយ ។ រើខ្លួន = កែវាសនារបស់យើងដែលធ្លាប់តែថោកទាប ឲ្យទៅជាថ្លៃថ្នូរឡើងវិញ ។ ខំក្រើន = ប្រមែប្រមូលពីអ្នកដទៃឲ្យបានច្រើនឡើង ។ ធ្លាក់ស្មៀត = ឃ្លាតឆ្ងាយពីសេចក្តីប្រុងប្រយ័ត្នឬអំពីមធ្យោបាយការពាររបស់យើង ។

## ៣– ដម្លៃរបស់វិជ្ជា (បទបំណែ)

វិជ្ជាស្នេហ៍ប្រសើរ បើទុកជាដើរទៅស្រុកភូមិណា
កើតទ្រព្យកើតស្បៀងអាហារ ចោរកាចឫស្យាប្រាថ្នាមិនបាន ។
ចេះគួរគ្នាយើងខំប្រឹង ព្យាយាមឲ្យតឹងកុំបីឈប់ខាន
រៀនសូត្រឲ្យចេះគ្រប់ប្រាណ យូរៗគង់បានដូចក្តីប្រាថ្នា ។
កើតមកក្នុងនាលោកកិយ ទោះប្រុសឬស្រីរូបល្អយ៉ាងណា
បើមិនចេះវិជ្ជាការ អ្នកប្រាជ្ញលោកថាកើតឥតប្រយោជន៍ ។

ពាក្យពន្យល់ វិជ្ជាការចេះដឹង ។ ស្នេហ៍ប្រសើរ (ម.ថ. ស្នេ) មន្តដែលគេប្រសិទ្ធីឲ្យអ្នកដទៃស្រឡាញ់រាប់អានគ្រប់គ្នា ។ ចោរកាចឫស្យា ចោរដែលមានចិត្តកំណាចលើសចោរធម្មតា បើទុកជាអ្នករងគ្រោះសំពះអង្វរយ៉ាងណាៗក៏មិនមានអាណិតមេត្តាលោះលាគ្រាប្រណីឡើយ ។ ព្យាយាម- ខំធ្វើខំរៀនមិនលះបង់ចោល ។ លោកិយ (ម ថ. លោកកី)= កើតមកជាមនុស្សប្រកបដោយខន្ធ ៥ ហើយដែលមានសន្តានចិត្តញាប់ញ័រ, យេង- យោង រើរវាយ, ប្រែប្រួល ។ កើតឥតប្រយោជន៍= កើតមកឲ្យតែបង្អៀតផែនដី ឥតមានធ្វើអ្វីឲ្យជាប្រយោជន៍ដល់ប្រទេសជាតិឡើយ ។

ម៉ែន – ទង់
គ្រូបង្រៀន នៅសាលាជើងឆ្នុក
ឃុំតាំងគោក ស្រុកជើងព្រៃ (កំពង់ចាម)

រោងពុម្ពខ្មែរ